

# ពាន់ឆ្នាំ

## ទំនាក់ទំនង កម្ពុជា-ចិន

(បុរេប្រវត្តិ - រាជ្យព្រះស្ដេចកាន)

# 千年友好 中柬交流史话

(远古时代——甘帝)

ISBN 9789996359538

ការផ្សាយរបស់វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា
រាជធានីភ្នំពេញ ឆ្នាំ២០១២
www.cirac.edu.kh

បោះពុម្ពលើកទី១

## មាតិកា


-សេចក្ដីថ្លែងអំណរគុណ ........ ក

-អារម្ភកថា ........ ខ

-សេចក្ដីផ្ដើម ........ ០១

-ជំពូកទី១ ៖ សម័យបុរេប្រវត្តិសាស្ត្រ ........ ០២

១.១-យុគថ្មរំលីង ........ ០២

១.១.១-ត្បាល់បុក ........ ០៣

១.១.២-គ្រឿងអលង្ការធ្វើពីថ្មយក់ ........ ០៥

១.១.៣-រហាត់ទឹក ........ ០៧

១.២-យុគលោហៈ ........ ០៨

១.២.១-ស្គរមហោរធឹកសំរិទ្ធ ........ ០៨

១.២.២-សិប្បកម្មមាស ........ ១៣

-ជំពូក២ ៖ សម័យហ្វូណន - រាជ្យព្រះស្ដេចកន ........ ១៧

២.១-វប្បធម៌ ........ ១៩

២.១.១-ក្រមាខ្មែរ ........ ១៩

២.១.២-ពុទ្ធបដិមា ........ ២២

២.១.៣-កង់រទេះគោ ........ ២៦

២.១.៤-កុលាលភាជន៍ ........ ២៨

២.១.៥-តន្ត្រី ........ ៣០

២.១.៦-ល្បែងផ្គិនភ្នែក ........ ៣៣

២.១.៧-ចក្រសត្វទាំង១២ ........ ៣៤

២.១.៨-កាំជ្រួច និង ផាវ ........ ៣៧

២.១.៩-សូត្រចិន ........ ៣៧

២.១.១០-ការយល់ច្រឡំរបស់ជនជាតិចិន ........ ៣៨

២.២-នយោបាយ ........ ៤២

២.២.១-កិច្ចគាំទ្រនយោបាយចិនតែមួយ ........ ៤២

២.២.២-កិច្ចការពារជនជាតិចិន ........ ៤៤

២.២.៣-ការរារាំងរបស់អណ្ដាមនិងចម្ប៉ា ........ ៤៦

២.២.៤-ទំនាក់ទំនងវិស័យយោធា ........ ៤៦

២.៣-សេដ្ឋកិច្ច ........ ៤៨

២.៣.១-ពាណិជ្ជកម្ម ........ ៤៨

២.៣.២-ដៃគូអភិវឌ្ឍ ........ ៥០

-សន្និដ្ឋាន ........ ៥២


**<u>អធិប្បាយក្របមុខ</u> ៖ ប្រាសាទអង្គរវត្ត និងមហាកំផែង**
**បោះពុម្ពលើកទី១ ចំនួន ១.០០០ក្បាល ដោយរោងពុម្ពជោគជ័យ**

# សេចក្ដីថ្លែងអំណរគុណ

តាងនាមឱ្យក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលស្រាវជ្រាវប្រវត្តិសាស្ត្រនិងវប្បធម៌ខ្មែរ យើងខ្ញុំសូមថ្លែងអំណរគុណ ៖

១- សម្ដេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្ដល់ឱកាសដល់ការបង្កើតវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា។

២- ឯកឧត្ដមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដែលតែងតែគាំទ្រដល់បេសកកម្មការងាររបស់វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា។

៣- លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លូត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដែលបានផ្ដល់ឯកសារ និង គំនិតស្រាវជ្រាវនេះ។

៤- លោក **ចឹង ស៊ែង** លេខាបក្សសាកលវិទ្យាល័យជីវជាំង និងលោក **ភាន ស៊ាវឈីង** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជីវជាំង ដែលបានគាំទ្រដល់ការស្រាវជ្រាវនេះ។

៥- ឯកឧត្ដម **ពុង ឃាវសែ** អគ្គនាយកធនាគារកាណាឌីយ៉ា លោកស្រី **អ៊ឹង ស៊ីវហ្វួរ** ប្រធានក្រុមហ៊ុនស៊ុយតាយរ៉ុកហ្វេកធីវី ដែលបានគាំទ្រដល់បេសកកម្មការងាររបស់វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា។

៦- លោក **ហ៊ូ ជានហៃ** ប្រធានសមាគមពាណិជ្ជកម្មឧស្សាហកម្មខេត្តជីជាំង ប្រចាំកម្ពុជា ដែលបានជួយរួមចំណែកឧបត្ថម្ភដល់ការបោះពុម្ពផ្សាយ។

ជាមួយនេះដែរ យើងក៏សូមថ្លែងអំណរគុណចំពោះវាគ្មិនក្នុងសន្និសីទអន្តរជាតិលើកទី១ **ស្ដីពីទំនាក់ទំនងកម្ពុជា-ចិននាសម័យចេនឡានិងអង្គរ** (ឧបត្ថម្ភដោយ**វិទ្យាស្ថានខុងជឺទីស្នាក់ការកណ្ដាល** កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ នៅរាជបណ្ឌិត្យសភាកម្ពុជា) ដែលបានផ្ដល់នូវឯកសារនិងគំនិតក្នុងការស្រាវជ្រាវនេះ។

លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណចំពោះស្ថាប័ន ដែលបានជួយឧបត្ថម្ភដល់ការបោះពុម្ពផ្សាយឯកសារស្រាវជ្រាវនេះ ៖

វិទ្យាស្ថានខុងជឺ
ទីស្នាក់ការកណ្ដាល

សាកលវិទ្យាល័យ
ជីវជាំង

# អារម្ភកថា

ចំពោះអ្នកដែលប្រាថ្នាចង់ដឹង ចង់ស្គាល់ និងចង់យល់អំពីឥទ្ធិពលនៃវប្បធម៌ឥណ្ឌាលើប្រជាជនខ្មែរ គេពិតជាមិនពិបាកនឹងរកបានឯកសារសំខាន់បញ្ជាក់ទេព្រោះថាសំណេរគ្រប់ប្រភេទមានយ៉ាងច្រើនសន្ធឹកសន្ធាប់នៅតាមបណ្ណាល័យ ឬនៅតាមបណ្ណាគារនានា។ ប៉ុន្តែផ្ទុយទៅវិញ រហូតដល់សព្វថ្ងៃនេះ បើសិនជាគេប្រាថ្នាចង់ស្វែងយល់អំពីឥទ្ធិពលចិនលើខឿនវប្បធម៌ខ្មែរដើមទៅវិញនោះគេពិតជាពិបាករកបានអ្វីដែលគេចង់ស្វែងយល់ណាស់។

កន្លងមក មានការបកប្រែកំណត់ហេតុចិន ស្តីពី **ហ្វូណន** របស់លោក **ប៉ុល ប៉េល្លីយ៉ូត** នៅឆ្នាំ១៩០៣ និងកំណត់ហេតុរបស់លោក **ជីវតាក្វាន់** បកប្រែដោយលោក **លី ធាមតេង** ក៏មែនពិត ក៏ប៉ុន្តែ ពុំទាន់មានការស្រាវជ្រាវណាមួយបង្ហាញឥទ្ធិពលចិនមកលើសង្គមខ្មែរនៅឡើយ។

បើយើងសម្លឹងមើលអតីតកាលវិញនោះ ហើយយកភូមិសាស្ត្រ ប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែរកត់ត្រាដោយចិនមកលាតត្រដាងមើល យើងនឹងយល់ដឹងអំពីតួនាទីនិងសារៈសំខាន់របស់ប្រជាជនខ្មែរនិងចិនក្នុងសម័យបុរាណពុំខាន។ សម្ព័ន្ធភាពរវាងខ្មែរ-ចិនតែងឈរលើកត្តាសេដ្ឋកិច្ចនិងវប្បធម៌ដូចទំព័រប្រវត្តិសាស្ត្រចាស់ បានឆ្លុះបញ្ចាំងជាសក្ខីភាពស្រាប់។

ទោះបីជាវប្បធម៌ខ្មែរបានទទួលឥទ្ធិពលវប្បធម៌ចិន ដែលមានកម្រិតទាបក្តីខុសពីឥទ្ធិពលឥណ្ឌាក៏ដោយតែចំណងមិត្តភាពកម្ពុជា-ចិន ក៏មានភាពចំណាស់ផងដែរ។ ហេតុនេះហើយ ទើបយើងព្យាយាមចងក្រងឯកសារនេះឡើង ដើម្បីបង្កើតសម្មិតិកម្មថ្មីមួយឡើងបន្ថែមទៀត។ ការយល់ដឹងអំពីឥទ្ធិពលចិននៅតែមានលក្ខណៈចាំបាច់ ក្នុងការពង្រីកនិងពង្រឹងពុទ្ធិមនុស្សជាតិ។ ការស្រាវជ្រាវនេះគ្រាន់តែជាការចាប់ផ្តើមឬផ្តួចផ្តើមនូវការសិក្សាដែលមានវិសាលភាពដ៏ធំធេងមួយនេះ។

បំណងតែមួយគត់នៃការស្រាវជ្រាវនេះ គឺបន្តសំណង់មហិមានៃស្ពានទំនាក់ទំនងកម្ពុជា- ចិន។ ការស្រាវជ្រាវនេះជាផ្រុងមួយដ៏តូចនៃការរំឭកពីទំនាក់ទំនងកម្ពុជា-ចិន។ ការស្រាវជ្រាវនេះពិតជាមិនអាចគេចវៀសផុតពីកំហុសឆ្គងផ្នែកទម្រង់និងខ្លឹមសារនោះឡើយ។

ជាអវសាន្ត យើងខ្ញុំសូមស្វាគមន៍យ៉ាងរីករាយរាល់មតិយោបល់របស់អ្នកសិក្សាស្រាវជ្រាវដើម្បីធ្វើសុក្រឹតកម្មលើស្នាដៃនេះ។

**សហនាយកវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា**

# **សេចក្តីផ្តើម**

កម្ពុជា និងចិន បានផ្សារភ្ជាប់ទំនាក់ទំនងរវាងគ្នានិងគ្នា ជាយូរណាស់មកហើយ។ កំណត់ត្រារបស់លោក **កាំងថៃ** (រាជទូតចិនមកបំពេញទស្សនកិច្ចនៅហ្វូណន) និងកំណត់ត្រារបស់ លោក **ជីវតាក្វាន់** (រាជទូតចិនមកបំពេញទស្សនកិច្ចនៅអង្គរ) ជាសក្ខីភាពបង្ហាញស្រាប់។ បើតាមការសិក្សាពីបុរាណវត្ថុ បុរាណវិទូមួយចំនួនដូចជាលោកបណ្ឌិត **មីសែល ត្រាណេ** បានបញ្ជាក់ថា ៖ ទំនាក់ទំនងរវាងកម្ពុជានិងចិន មានប្រវត្តិមុនកំណត់ត្រារបស់រាជទូតចិនខាងលើទៀតផង។

ខែមិថុនា ឆ្នាំ២០១១ ក្នុងឱកាសដែលគណៈប្រតិភូរាជបណ្ឌិត្យសភាកម្ពុជាទៅសម្ពោធស្លាកមជ្ឈមណ្ឌលស្រាវជ្រាវប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែរនៅសាកលវិទ្យាល័យជីវជាំង លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លូត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បានធ្វើបទបឋកថាស្តីពីទំនាក់ទំនងកម្ពុជា-ចិនរយៈពេល២.០០០ឆ្នាំ។

ទំនាក់ទំនងកម្ពុជា-ចិនផ្អែកលើវិស័យសេដ្ឋកិច្ចនិងវប្បធម៌ គ្មានមហិច្ឆិតាឈ្លានពានវាតទីកដី ដែលធ្វើឱ្យតាំងពីបុរេប្រវត្តិរហូតមកដល់បច្ចុប្បន្ន។ ស្ពានមេត្រីរវាងកម្ពុជានិងចិនរមែងតែងនាំមកនូវសុខសន្តិភាព វឌ្ឍនភាព ដែលគេអាចចាត់ទុកថាជាគំរូឱ្យប្រទេសជិតខាងមើល សម្រាប់កាត់បន្ថយភាពប្រទូស្តរាយ ឬភាពអមិត្ត។ ប្រទេសកម្ពុជាបានរក្សាទំព័រប្រវត្តិសាស្ត្រនៃទំនាក់ទំនងជាមួយប្រទេសចិន យ៉ាងហោចណាស់ក៏ជាង២.០០០ឆ្នាំមកហើយ។

# ជំពូក ១

# សម័យបុរេប្រវត្តិសាស្ត្រ

## ១.១-យុគថ្មរំលីង

ប្រវត្តិនៃទំនាក់ទំនងវប្បធម៌ខ្មែរ-ចិនត្រូវបានបញ្ជាក់ជាទូទៅ តាមរយៈវិស័យបុរាណវិទ្យា ដូចជាឧស្សាហកម្មថ្មជាដើមដោយបានផ្តល់ព័ត៌មានដ៏សំខាន់ៗ អំពីលក្ខណៈនៃវប្បធម៌បុរាណ ក្នុងភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ។ ថ្មីៗនេះ ការសិក្សាប្រៀបធៀបអំពីអាវុធថ្មមួយចំនួនបានបង្ហាញឱ្យយើងយល់យ៉ាងជាក់ច្បាស់ អំពីប្រវត្តិនៃការវិវត្តនៃឧបករណ៍ធ្វើអំពីថ្មរបស់ប្រជាជនខ្មែរ នាសម័យបុរេប្រវត្តិ។

ការសិក្សាវិភាគអំពីបុរាណវត្ថុនាយុគថ្មរំលីងដែលគេបានរកឃើញនៅក្នុងភូមិភាគខាងត្បូងនៃប្រទេសចិនមានលក្ខណៈប្រហាក់ប្រហែលនឹងបុរាណវត្ថុនៅស្ថានីយបុរេប្រវត្តិសាស្ត្រនៅក្នុងទឹកដីហ្វូណន។ នេះបានបញ្ជាក់ថាទំនាក់ទំនងកម្ពុជា-ចិន បានផ្តើមឡើងយ៉ាងហោចណាស់ក៏នៅដើមសម័យថ្មរំលីង ហើយត្រូវបានបន្តរហូតដល់សម័យទំនើប ដោយបានឆ្លងកាត់ដំណាក់កាលវិវត្តជាច្រើន តាមសម័យនៃប្រវត្តិសាស្ត្រ។

ក្នុងន័យនេះ យើងអាចនិយាយបានថាប្រវត្តិនៃទំនាក់ទំនងវប្បធម៌រវាងកម្ពុជា-ចិន គឺជាប្រវត្តិនៃការផ្លាស់ប្តូរបច្ចេកវិទ្យាជាទូទៅនិងឧបករណ៍ប្រើប្រាស់ដូចជា ពូថៅថ្មមានដង និងឥតដងដែលបុព្វបុរសខ្មែរបានប្រើប្រាស់ប្រមាណតាំងពី៣.០០០ឆ្នាំមុនគ្រិស្តសករាជរហូតដល់សតវត្សទី៥នៃគ្រិស្តសករាជ ពោលគឺមុនការលេចធ្លោឡើងនៅយុគវប្បធម៌លោហធាតុ ។

ចាប់តាំងពី២.០០០ឆ្នាំមុនគ្រិស្តសករាជ មិនចំពោះតែក្នុងប្រទេសចិនប៉ុណ្ណោះទេ សូម្បីតែក្នុងឧបទ្វីបឥណ្ឌូចិន វប្បធម៌ចាប់ផ្តើមមានការរីកចម្រើនយ៉ាងមាំមួនបំផុត។ ការដុះដាលនេះគឺដោយសារតែអត្ថិភាពនៃវិស័យកសិកម្មដែលតម្រូវឱ្យមានការផលិតឧបករណ៍ប្រើប្រាស់មានប្រសិទ្ធភាពខ្ពស់ជាងសម័យមុនៗ ដូចជាការផលិតពូថៅឬពន្លួញធំៗអំពីថ្មសម្រាប់ធ្វើស្រែចម្ការឬការកាប់ឈើសម្រាប់សាងសង់លំនៅស្ថានជាដើម។

ឧស្សាហកម្មថ្មរំលីងដែលបានបង្កើតឡើង ដើម្បីកសិកម្មបាននាំមកនូវភាពរឹងប៉ឹងនៃសហគមន៍ ដោយជាប្រភពនៃវឌ្ឍនភាពផងដែរ។ ភូមិភាគខាងត្បូងនៃប្រទេសចិនបច្ចុប្បន្ន និងប្រជាជននៅឥណ្ឌូចិន ដែលជាបុព្វការីជនរបស់អម្បូរមន-ខ្មែរបានប្រើឧបករណ៍ដូចគ្នានេះ ជា

ការបញ្ជាក់ថាពួកគេធ្លាប់មានទំនាក់ទំនងជាមួយគ្នាយ៉ាងពិតប្រាកដ។ កាលបើបច្ចេកវិទ្យាមកពីចិនបានជ្រួតជ្រាបចូលទៅក្នុងសហគមន៍មន-ខ្មែរទាំងឡាយនៃជ្រោយសុវណ្ណភូមិ ដែលក្រោយមកបានឈ្មោះថា **ហ្វូណន** (នគរភ្នំ) **លិនយី** (ចម្ប៉ា) និង **ស្រីក្សេត្រ** (ភូមា) បុព្វការីជនខ្មែរបានប្រើប្រាស់ឧបករណ៍ដូចគ្នានឹងប្រជាជនចិនបុរាណ។ ទំនាក់ទំនងនេះអាចនឹងត្រូវបានប្រព្រឹត្តឡើងនៅសម័យដើមកំណើតនៃវប្បធម៌-អារ្យធម៌ខ្មែរម្លេះ ពោលគឺសម័យយុគថ្មរំលីង។ ជាឧទាហរណ៍ យើងឃើញមានពន្លួញថ្មមានដងសម្រាប់ភ្ជួរ ដែលគេបានជួបប្រទះយ៉ាងច្រើននៅក្នុងបណ្តាស្ថានីយបុរេប្រវត្តិសាស្ត្រនៅឥណ្ឌូចិន និងប្រទេសដូចគ្នានៅស្ថានីយបុរេប្រវត្តិចិនជាពិសេសនៅ **យ៉ាំងហ្សេ** ។ មួយវិញទៀត បើតាមការសិក្សាប្រៀបធៀបលក្ខណៈនៃកុលាលភាជន៍នាសម័យនវសិលា ជាពិសេស ភាជន៍មានជើងធ្វើអំពីដីពណ៌ខ្មៅហើយលម្អដោយក្បាច់គូទខ្សែង នៅភូមិសំរោងសែន ភូមិបានឈាង (ប្រទេសថៃបច្ចុប្បន្ន) និងភាជន៍នាសម័យ **សៀ** (XIA) និងហ្សូខាងលិច (ZHOU) យើងក៏អាចសន្និដ្ឋានបានថាទំនាក់ទំនងវប្បធម៌គឺពិតជាត្រូវបានកើតឡើងក្នុងសម័យនោះដែរ។

ដូច្នេះ តាមការពិនិត្យវិភាគស្លាកស្នាមវប្បធម៌បុរាណទាំងនោះឃើញថាលក្ខណៈនៃវត្ថុប្រើប្រាស់ទាំងនោះ ថ្វីត្បិតតែមានដើមកំណើតផ្សេងគ្នាមែនពិត ក៏ប៉ុន្តែទំនងទទួលឥទ្ធិពលពីចិនយ៉ាងប្រាកដ ព្រោះត្រូវបានផលិតឡើង ក្នុងសម័យកាលក្នុងជំនាន់តែមួយ ឬក៏ក្រោយមកបន្តិច។

### ១.១.១-ត្បាល់បុក

**ត្បាល់បុក** គឺជាឧបករណ៍ដែលជនជាតិខ្មែរបានផលិត ហើយប្រើប្រាស់តាមស្រុកភូមិខ្មែរតាំងពីបុរាណកាលរហូតមកដល់សព្វថ្ងៃ។ ជាការពិតណាស់ ដែលឧបករណ៍នេះគឺជាស្នាដៃដ៏ប្រពៃនិងប៉ិនប្រសប់របស់បុព្វការីជនខ្មែរ ដែលប្រកបដោយគំនិតច្នៃប្រឌិតយ៉ាងខ្ពង់ខ្ពស់។ ការនិយមឧបករណ៍នេះនៅតាមជនបទនៃប្រទេសកម្ពុជា បង្ហាញពីអត្ថប្រយោជន៍ជាក់ស្តែងក្នុងខណៈដែលប្រជាជនខ្មែរភាគច្រើនជាកសិករ។

យោងតាមទិន្នន័យផ្នែកជាតិពន្ធុវិទ្យា បានបញ្ជាក់ថាជនជាតិចិនមានការប្រើប្រាស់ **ត្បាល់បុកស្រូវ** តាំងពីសម័យរាជវង្ស **ហាន** ហើយវិវត្តរហូតដល់សម័យទំនើបយើងនេះ។ យ៉ាងណាមិញ សហគមន៍ជនជាតិអម្បូរចិនភាគតិច ដូចជា ពួកការៀង និងលីសូក្នុងប្រទេសថៃបច្ចុប្បន្ន ដែលជាជនជាតិអន្តោប្រវេសន៍ថ្មីក្នុងតំបន់ ក៏បានប្រើប្រាស់សម្ភារៈទាំងនោះដែរ។

ដូចពោលខាងលើភាពចំណាស់និងទីតាំងនៃការប្រើប្រាស់ត្បាល់បុកស្រូវបានបញ្ជាក់តាមរយៈផ្ទាំងគំនូរលើថ្មបុរាណដែលថាស្លាកស្នាមនៃមរតកវប្បធម៌ចិន ដែលខ្មែរបានទទួលឥទ្ធិពលយ៉ាងពិតប្រាកដ។ ដូច្នេះជនជាតិខ្មែរបានទទួលយកបច្ចេកវិទ្យាពីចិនក្នុងដំណើរវិវត្តនៃសង្គមក្នុងអតីតកាលមួយដែលគេពិបាកកំណត់សម័យកាលឱ្យបានជាក់ច្បាស់។ ចំណុចដែលគួរឱ្យចាប់អារម្មណ៍មួយទៀត គឺតាមការសិក្សានៅតាមភូមិស្រុកខ្មែរបានបញ្ជាក់ឱ្យឃើញថាឧបករណ៍ខាងលើនេះរបស់ខ្មែរមានលក្ខណៈសម្បត្តិមិនខុសគ្នានឹងឧបករណ៍នៅចិនឡើយ។

រហូតមកដល់សព្វថ្ងៃ ការប្រើប្រាស់ឧបករណ៍ទាំងនោះត្រូវបានបន្តដោយអ្នកស្រុកស្រែចម្ការខ្មែរនៅកម្ពុជា សហគមន៍ខ្មែរនៅប្រទេសវៀតណាមខាងត្បូង និងនៅខ្ពង់រាបនគររាជបច្ចុប្បន្ន។ ភូមិភាគខាងត្បូងនៃប្រទេសចិនធ្លាប់មានទំនាក់ទំនងវប្បធម៌ជាមួយប្រជាជនខ្មែរ



ត្បាល់បុកស្រូវ ( ប្រភព ៖ www.cen.com.kh )

នាសម័យបុរាណ គឺជាទីតាំងដែលបានបង្កើតឧបករណ៍ត្បាល់បុកឡើងជាលើកដំបូងបង្អស់។ ដូច្នេះហើយ ប្រភពនិងសារសំខាន់នៃត្បាល់បុកស្រូវនៃប្រទេសខ្មែរត្រូវផ្សារភ្ជាប់ជាមួយវប្បធម៌ចិន។ នេះជាអ្វីមួយដែលត្រូវបានយើងវាយតម្លៃយ៉ាងខ្ពស់ ដើម្បីស្វែងយល់អំពីទំនាក់ទំនងវប្បធម៌យ៉ាងជាប់លាប់រវាងកម្ពុជានិងចិនក្នុងអតីតកាលដ៏យូរលង់មួយទំនងជាត្រូវបានអនុវត្តឡើងតាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្ល៉េះ។

ខុសពីត្បាល់បុកធ្វើអំពីឫស្សី ប្រទេសកម្ពុជាមានប្រភេទត្បាល់កិនមួយប្រភេទទៀតដែលធ្វើអំពីថ្ម ហើយសព្វថ្ងៃនេះភាគច្រើនត្រូវបានផលិតនៅខេត្តកំពតសម្រាប់កិនម្សៅ។ ត្បាល់បុកនិងត្បាល់កិននេះក៏មានប្រភពចេញពីភូមិភាគខាងត្បូងនៃប្រទេសចិន។ គេអាចកិន

អង្គុរឱ្យក្លាយជាម៉ៅ្របានដោយសារចលនាបង្វិលផ្នែកខាងលើ ដោយបង្កាន់ដៃមួយធ្វើអំពីឈើ។ រីឯផ្នែកខាងក្រោមនៅនឹងមួយកន្លែង។ ត្បាល់កិននេះគ្មានក្បាច់ក្បូរអ្វីទាំងអស់គ្រាន់តែថ្មមានលក្ខណៈរលោងដោយសារការរំលីងតែប៉ុណ្ណោះ(១)។

### ១.១.២-គ្រឿងអលង្ការធ្វើអំពីថ្មយក់

**ថ្មយក់** គឺជាប្រភេទថ្មម៉្យាងដែលមានលក្ខណៈពិសិដ្ឋ សម្រាប់ប្រជាជនចិនក្នុងសម័យបុរាណកាលដ៏យូរលង់។ ការនិយមថ្មនេះដោយជនជាតិចិន គឺបានចាត់ទុកថាវាជាតំណាងភាពត្រជាក់ត្រជុំ សម្បូរសប្បាយគ្រប់ប្រការ មិនគ្រាន់តែជាតិនេះទេថែមទាំងជាតិនានាឯទៀតនៅបរលោក។ លើសពីនេះវាជានិមិត្តរូបនៃភាពអមតៈនៃជីវិត។

ដោយសារមូលហេតុចម្បងនេះហើយ ទើបនាសម័យបុរាណគេយកថ្មនេះមកយកឆ្លាក់ជាគ្រឿងអលង្ការ (កងដៃ កងជើង ក្រវិលត្រចៀក រូបសត្វ ឬក៏វត្ថុមានតម្លៃផ្សេងៗមួយចំនួន) ហើយដែលគេបានជួបប្រទះក្នុងផ្នូរសពរបស់ពួកអភិជន ឬព្រះមហាក្សត្រ។

ការធ្វើកំណាយនៅស្ថានីយបុរេប្រវត្តិសាស្ត្រមួយចំនួន នៅក្នុងអតីតដីខ្មែរ (ប្រទេសថៃបច្ចុប្បន្ន) ក៏ដូចនៅប្រទេសកម្ពុជា ជាពិសេសនៅភូមិស្នាយក្នុងខេត្តបន្ទាយមានជ័យ បានផ្តល់នូវប្រយោជន៍សំខាន់ៗជាច្រើន ភស្តុតាងនិងស្លាកស្នាមនៃពាណិជ្ជកម្មអន្តរជាតិរវាងខ្មែរនិងចិននាចុងសម័យលោហធាតុ និងដើមសម័យប្រវត្តិសាស្ត្រ។ ចំពោះយើងក្រវិលត្រចៀកមួយចំនួននិងកងដៃធ្វើអំពី **ថ្មយក់** គឺជាទិន្នន័យមួយគួរឱ្យចាប់អារម្មណ៍ថ្វីត្បិតគ្រាន់តែជាផ្នែកមួយសំខាន់នៃប្រព័ន្ធដ៏សម្បូរបែបនៃការផ្លាស់ប្តូរវប្បធម៌រវាងជនជាតិទាំងពីរក៏ដោយ។

ដោយសារតែវត្តមានរបស់គ្រឿងអលង្ការធ្វើអំពីថ្មយក់នៅក្នុងប្រទេសកម្ពុជា ខ្លះមានលក្ខណៈស្រដៀងនឹងអ្វីដែលប្រជាជនចិនបុរាណពេញនិយម ហើយដោយសារនៅប្រទេសខ្មែរសព្វថ្ងៃពុំមានការដ្ឋាន **ថ្មយក់** បែបនេះ យើងយល់ថាថ្មនេះមានប្រភពចេញពីប្រទេសចិនយ៉ាងប្រាកដ។

ការណ៍ដែលគេបញ្ចុះគ្រឿងអលង្ការធ្វើអំពីថ្មយក់ ក្នុងផ្នូរសពកាន់តែធ្វើឱ្យយើងស្គាល់តម្លៃវប្បធម៌ដ៏ជ្រាលជ្រៅជាក់ស្តែងរបស់ប្រភេទអលង្ការទាំងនេះ។ ម៉្យាងវិញទៀត វត្តមានរបស់គ្រឿងអលង្ការទាំងនោះក៏នាំឱ្យយើងរកឃើញភស្តុតាងថ្មីមួយទៀត ធ្លាប់ជាសម្ព័ន្ធភាពរវាង

---

(១) www.cen.com.kh/Culture

ខ្មែរនិងចិនមុនការកកើតឡើងនៃរដ្ឋខ្មែរដំបូងបង្អស់ ដែលចិនដាក់ឈ្មោះថា **ហ្វូណន** ផងដែរ។

ដោយឡែក បើតាមរបកគំហើញខាងបុរាណវិទ្យា ក្រៅពីថ្មយក់ ខ្មែរមានអង្កាំធ្វើអំពីកែវ និងថ្មដែលមានពណ៌ចម្រុះនោះ ហើយការនិយមអង្កាំត្រូវបានផ្សព្វផ្សាយទូទាំងឧបទ្វីបឥណ្ឌូចិន និងឥណ្ឌូនេស៊ីថែមទៀតផង ពោលគឺក្នុងបរិវេណភូមិសាស្ត្រដ៏ធំធេងមួយ ហើយបរិមាណអង្កាំក៏មានចំនួនដ៏ច្រើនលើសលប់ឥតគណនា ក្នុងសម័យបុរាណមានរយៈកាលប្រមាណដោយជា២.៣០០ឆ្នាំមកហើយ ។

យើងបានរកឃើញថាអង្កាំគ្រប់ប្រភេទត្រូវបានចែកចាយតាមរយៈពាណិជ្ជកម្មនៅតាមស្ថានីយប្រវត្តិសាស្ត្រសំខាន់ៗ នៅក្នុងឈូងសមុទ្រសៀមសព្វថ្ងៃ ក៏ដូចនៅក្នុងតំបន់ដងទន្លេចៅប្រាយ៉ា ជាពិសេសនៅទីក្រុងអ៊ូថង ក្នុងខេត្តសុផាន់បុរីសព្វថ្ងៃ ព្រមទាំងនៅអង្គរបុរីជាដើម។



អលង្ការធ្វើពីថ្មយក់ (ប្រភព ៖ បណ្ឌិត មីសែល ត្រាណេ)

### ១.២.៣-រហាត់ទឹក

តាំងពីសម័យបុរាណកាលមក ឧបករណ៍មួយចំនួនត្រូវបានគេជួបប្រទះ ក្នុងជីវភាពប្រចាំថ្ងៃដូចជា រទេះគោ រទេះសេះ និងរហាត់ទឹកសម្រាប់វិស័យកសិកម្មជាដើម។ នៅតាមផ្លូវទៅកាន់ប្រាសាទ អ្នកដំណើរបានជួបនឹងរហាត់ទឹកដ៏ធំមួយ ហើយរូបភាពនេះយើងឃើញមាននៅប្រទេសចិនខាងត្បូងនិងនៅវៀតណាមខាងជើងសព្វថ្ងៃនេះ។ ជុំវិញវត្ថុមានរបស់រហាត់ទឹកនេះ អ្នកនិពន្ធខ្លះបានចាត់ទុកថាជាស្នាដៃដ៏ប៉ិនប្រសប់របស់បុព្វការីជនខ្មែរនាសម័យបុរាណ។



រហាត់ទឹកក្នុងរជ្ជកាលហាន (ប្រភព ៖ បណ្ឌិត មីសែល ត្រាណេ)

រហាត់ទឹកនៅខេត្តសៀមរាបអង្គរ ធ្វើឡើងសម្រាប់បម្រើវិស័យទេសចរណ៍ច្រើនជាងបម្រើវិស័យកសិកម្ម។

ជាការពិតណាស់ ឧបករណ៍ខាងលើនេះ មានអត្ថប្រយោជន៍សម្រាប់ការបង្ហូរទឹកចូលក្នុងស្រែដែលជនជាតិចិនបានបង្កើតឡើង ប្រកបដោយទេពកោសល្យនិងការច្នៃប្រឌិតខ្ពស់។ ប៉ុន្តែចំពោះប្រទេសកម្ពុជាវិញ ពុំទាន់មានការស្រាវជ្រាវណាមួយបញ្ជាក់ពីការនិយមរហាត់ទឹកដោយបុព្វការីជនជាតិខ្មែរនៅឡើយ ជាពិសេសខាងវិស័យកសិកម្ម។ ទោះបីជាមានឯកសារ

មួយចំនួនបានអះអាងថារហាត់ទឹកនៅខេត្តសៀមរាបមានលំនាំដូចរហាត់ទឹកនៅភូមិភាគខាងត្បូងនៃប្រទេសចិនយ៉ាងណាក៏ដោយ ក៏យើងមិនអាចបញ្ជាក់ថា ដូនតាខ្មែរពិតជាបានខ្ចីឧបករណ៍សំខាន់ នេះពីជនជាតិចិនឡើយ។ មូលហេតុដែលបណ្តាលឱ្យយើងសន្និដ្ឋានដូច្នេះ គឺមកពីបុព្វបុរសខ្មែរចេះបាចទឹកបញ្ចូលស្រែតាំងពីបុរេប្រវត្តិមកម្ល៉េះ។

ខាងលើនេះមានន័យថា ជនជាតិខ្មែរចេះផលិតរហាត់ទឹកដែលធ្វើអំពីឫស្សី ក៏ប៉ុន្តែមិនបានបង្កើតវានោះទេ។ ជនជាតិចិនបានបង្កើតរហាត់ទឹកនេះតាំងពីសតវត្សទី៣មុនគ្រិស្តសករាជ។ យើងមិនត្រូវចាត់ទុកថាកម្ចីបច្ចេកទេសខាងលើនេះគឺជារឿងចម្លែកនោះទេ។ នេះជាចំណេះដឹងថ្មីមួយដែលពាក់ព័ន្ធទៅនឹងសម្ព័ន្ធភាពរវាងប្រជាជនចិននិងប្រជាជនខ្មែរដែលមានអាយុកាលច្រើនសតវត្សមកហើយ។

ទាក់ទងនឹងរហាត់ទឹករនេះ តាមរយៈឯកសារជាច្រើនបានឱ្យដឹងថា ជនជាតិចិនបាននិយមឧបករណ៍នេះតាំងពីសម័យហានមកម្ល៉េះ ពោលគឺរវាងសតវត្សទី៣មុនគ្រិស្តសករាជ និងទី២ក្រោយគ្រិស្តសករាជ ដើម្បីចែកចាយទឹករបស់ខ្លួន[២]។

ជារួម បើយោងតាមរបកគំហើញខាងបុរាណវិទ្យា យើងបានដឹងថាទំនាក់ទំនងវប្បធម៌រវាងខ្មែរនិងចិន បានផ្តើមឡើងតាំងតែសម័យបុរេប្រវត្តិសាស្រ្ត។ ឆ្លងតាមការសិក្សាប្រៀបធៀបទៅលើវិស័យបុរាណវិទ្យានិងអារ្យធម៌ យើងអាចសន្និដ្ឋានថាមានទំនាក់ទំនងផ្នែកពាណិជ្ជកម្មរវាងប្រជាជនខ្មែរ និងចិនដែរ។

## ១.២-យុគលោហៈ

### ១.២.១-ស្ពានមហោរធឹកសំរិទ្ធ

**ស្ពានមហោរធឹកសំរិទ្ធ** (សំរិទ្ធគឺខ្មែរបុរាណបានយកធាតុផ្សំមានសំណលាយជាមួយស្ពាន់) ជាឫសកែវ ឬដួងព្រលឹងវប្បធម៌-អារ្យធម៌ជាតិសាសន៍ខ្មែរបុរាណដ៏យូរលង់។ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ ដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៨ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានធ្វើកំណាយបែបវិធីសាស្រ្តរកឃើញកុលាលភាជន៍ គ្រឿងអលង្ការធ្វើពីមាសនិងលោហធាតុដទៃទៀត រួមទាំងក្រវិលអង្កាំធ្វើអំពីថ្មមានតម្លៃ និងខ្នារអំបោះធ្វើអំពីដីដុតជាច្រើនមុខផ្សេងៗ

---

(២) www.cen.com.kh/Culture

ទៀតក្នុងផ្នូរបុរាណមួយនៅក្នុងស្ថានីយភូមិព្រហារ ឃុំជ្រៃ ស្រុកព្រៃវែង ខេត្តព្រៃវែង(៣)។ អាយុកាលរបស់ស្គរនេះមានទំហំមុខ៤០សង់ទីម៉ែត្រ និងកម្ពស់៣៥សង់ទីម៉ែត្របានត្រូវគេសន្និដ្ឋានថាប្រហែលស្ថិតក្នុងចន្លោះសតវត្សទី១ដល់សតវត្សទី៤ មុនគ្រិស្តសករាជ។ **ស្គរមហោរធឹក** នេះគឺជាការបង្ហាញពីទំនាក់ទំនងផ្នែកវប្បធម៌រវាងខ្មែរនិងចិននាសម័យបុរេប្រវត្តិសាស្ត្រ។ គួរបញ្ជាក់ផងដែរថាប្រជាជនកម្ពុជាធ្លាប់បានរកឃើញ **ស្គរមហោរធឹក** ធ្វើអំពីសំរិទ្ធនេះ ឬជាបំណែកបែបនេះជាច្រើនកន្លែងផ្សេងៗគ្នាដូចជានៅមេមត់ (ខេត្តកំពង់ចាម) កំពង់ស្ពឺ បន្ទាយមានជ័យ កម្ពុជាក្រោម (ប្រទេសវៀតណាម) ថៃ ឡាវ ឥណ្ឌូនេស៊ី ភូមា និងម៉ាឡេស៊ី។ វត្តមានរបស់ស្គរនេះ នៅភូមិព្រហារប្រហែលជាមិនត្រូវបានផលិតនៅនឹងកន្លែងផ្ទាល់តែម្តងទេ ដោយសារអវត្តមានរបស់ពុម្ព ក៏ប៉ុន្តែមានប្រភពមកពីប្រទេសចិនដែលជាទីកំណើតនៃប្រពៃណីផលិតនិងប្រើប្រាស់ស្គរនេះក្នុងពិធីសាសនា(៤)។



ស្គរមហោរធឹកសំរិទ្ធនៅស្ថានីយព្រហារ (ប្រភព ៖ បណ្ឌិត មីសែល ត្រាណេ)

(៣) បើតាមលោកបណ្ឌិត **មីសែល ត្រាណេ** បានបញ្ជាក់ថា ៖ នៅក្នុងសារមន្ទីរជាតិភ្នំពេញសព្វថ្ងៃនេះ មានស្គរមហោរធឹកចំនួន៣ និងនៅមជ្ឈមណ្ឌលបុរាណវិទ្យាមេមត់ ខេត្តកំពង់ចាម មានគេរើសបានបំណែកស្គរមហោរធឹកនេះមួយដុំដែរ។ ស្គរមហោរធឹកដែលគេយកមកដាក់តាំងក្នុងសារមន្ទីរជាតិនោះ គឺពុំមានលក្ខណៈបញ្ជាក់ទីតាំងច្បាស់លាស់ដូចនៅភូមិព្រហារទេ តែមានហេតុផលមួយចំនួនបង្ហាញថាគេបានមកពីខេត្តស្ទឹងត្រែង។ នៅលើស្ថានីយបុរេប្រវត្តិសាស្ត្រនេះ ប្រជាជនជីកបានស្គរមហោរធឹកចំនួនប្រហែល៣០។

(៤) www.cen.com.kh/Culture

របកគំហើញថ្មីដែលយើងសូមបញ្ជាក់នៅទីនេះគឺស្គរនេះ ក៏ពាក់ព័ន្ធទៅនឹងការបូជាសព ព្រោះ **ស្គរមហោរធឹក** ត្រូវបានប្រើសម្រាប់ដាក់ឆ្អឹងមនុស្សដែលបានស្លាប់ទៅ និងដាក់របស់របរសម្រាប់ប្រើប្រាស់នៅបរលោកទៅវិញ។ ស្គរនេះក៏ត្រូវបានគេចាត់ទុកជាកោដិបន្ថែមពីសភាពធម្មតាដែលត្រូវបានគេប្រើក្នុងពិធីសុំទឹកភ្លៀង។

តាមរយៈវត្ថុមាននៃស្គរមហោរធឹក យើងអាចសន្និដ្ឋានបានថា៖

១-វត្ថុមានតម្លៃនិងរបស់គ្រឿងអលង្ការផ្សេងៗធ្វើអំពីមាស ដែក ស្ពាន់ និងសំរិទ្ធ បញ្ជាក់ថាខ្មែរនាជំនាន់នោះមានភាពរុងរឿង ថ្កើងថ្កាន រីកចម្រើនខាងឧស្សាហកម្មលោហធាតុទៅហើយ ជាពិសេសការផលិតរបស់ធ្វើអំពីមាសនិងសំរិទ្ធ។



បំណែកស្គរមហោរធឹកសំរិទ្ធនៅស្ថានីយព្រហារ

(ប្រភព ៖ Andreas Reinecke, Vin Laychour, Seng Sonetra)

២-ផ្លែត្រល់ បញ្ជាក់ថាស្ត្រីខ្មែរមានជំនាញដេរប៉ាក់។

៣-វត្ថុមានឆ្អឹងលលាដ៍ និងធ្មេញ បញ្ជាក់ថានេះជាប្រពៃណីកប់សពលើកទី២ ព្រោះដំណាក់កាលទី១ គេបញ្ចុះសពក្នុងដី (ផ្នូរ) រួចហើយគេរើសយកឆ្អឹង ឬបំណែកសម្រាប់មកបញ្ចុះក្នុងស្គរកប់ម្តងទៀត។ ប្រពៃណីបែបនេះគឺជនជាតិខ្មែរនៅភូមិភាគឦសានបាននិងកំពុងពេញនិយម។

៤-វត្ថុមានរបស់ព្រះអាទិត្យរះនៅលើថាសនៃស្គរ បញ្ជាក់ពីលក្ខណៈពិសិដ្ឋរបស់ស្គរ

ដែលអាចជួយឱ្យអ្នកស្លាប់អាចនឹងកើតម្តងទៀត ដូចព្រះអាទិត្យដែលបានរះនាថ្ងៃស្អែកបន្ទាប់ពីបានលិចនាថ្ងៃនេះ។

យើងត្រូវទទួលស្គាល់ថា ស្គរទាំងនោះគឺជាភស្តុតាងប្រវត្តិសាស្ត្រមួយយ៉ាងសំខាន់ បង្ហាញបញ្ជាក់ប្រភពចិននៃស្គរទាំងនោះដែលគេបានរកឃើញក្នុងភូមិភាគនេះ ក៏ប៉ុន្តែលើសពីនេះទៅទៀត អត្ថិភាពនៃវិស័យពាណិជ្ជកម្មនាសម័យបុរេប្រវត្តិសាស្ត្រនេះ ជាការរកឃើញថ្មីបំផុតរបស់យើងតាមការវិភាគសិក្សាស្រាវជ្រាវដ៏ហ្មត់ចត់។ គួរំឭកដែរថានៅប្រទេសចិនបច្ចុប្បន្នគេបានជួបប្រទះ **ស្គរមហោរធឹកសំរិទ្ធធំជាងគេបំផុត** ដែលមានអាយុកាលប្រមាណ៧០០ឆ្នាំមុនគ្រិស្តសករាជ[៥]។

## ក-ការប្រើស្គរមហោរធឹកសំរិទ្ធក្នុងបរិបទខ្មែរ

ដូចពោលខាងលើ ជនជាតិខ្មែរមានការប្រាស្រ័យទាក់ទងជាមួយជនជាតិចិនបានទទួលឥទ្ធិពលវប្បធម៌ពីចិនសម័យបុរេប្រវត្តិសាស្ត្រមកម្ល៉េះ ដោយបានចាត់ទុកថាសត្វកង្កែបជានិមិត្តរូបនៃទឹកភ្លៀង ព្រោះពេលភ្លៀងធ្លាក់ម្តងៗ សត្វកង្កែបក៏ដូចជា សត្វហ៊ីង គីង្គក់បាននាំគ្នាស្រែកយំកងរំពងទ្រហឹង ហាក់បីដូចជាសម្តែងសេចក្តីសប្បាយ ឬក៏អង្វរកសុំទឹកភ្លៀងឱ្យឆាប់មក។ ប្រវត្តិវិទូជាច្រើនបានស្រាវជ្រាវឃើញថាការប្រើ **ស្គរមហោរធឹកសំរិទ្ធ** ហៅទឹកភ្លៀង កើតមានឡើងចាប់តាំងពីសម័យវប្បធម៌លោហធាតុដែលមានអាយុកាលរាប់ពាន់ឆ្នាំមុនគ្រិស្តសករាជ។ ក្នុងន័យនេះ មនុស្សចាស់បុរាណបានឱ្យឈ្មោះ **ស្គរមហោរធឹក** ធ្វើអំពីសំរិទ្ធទាំងនោះថា **ស្គរហៅទឹកភ្លៀង**។ ការតាំងឈ្មោះបែបនេះបានឆ្លុះបញ្ចាំងឱ្យយើងឃើញប្រព័ន្ធជំនឿរបស់ខ្មែរដើម។ និយាយម្យ៉ាងទៀត សម្ព័ន្ធភាពជិតស្និទ្ធរវាងសត្វកង្កែបដែលគេឆ្លាក់លើថាសស្គរហៅទឹកភ្លៀងខាងលើនេះ ក៏ជាវត្ថុបំណងឬសេចក្តីប្រាថ្នារបស់អ្នកស្រុកស្រែចម្ការ នាសម័យបុរាណដែរ។ ការណ៍នេះក៏បានបង្ហាញពីលក្ខណៈជាជីវចលនិយមមុនឥណ្ឌានីយកម្ម។ **ស្គរមហោរធឹកសំរិទ្ធ** បានបង្ហាញអត្ថិភាពរបស់វិស័យកសិកម្ម ខ្មែរដែលកើតចេញពីមូលដ្ឋានទឹកភ្លៀង ក្នុងចុងសម័យលោហធាតុនាដើមសម័យប្រវត្តិសាស្ត្រ ដោយបានផ្តើមឡើងចាប់តាំងពីសម័យវប្បធម៌ថ្មរំលីង។ ក៏ប៉ុន្តែអ្វីដែលសំខាន់នៅក្នុងបរិបទវប្បធម៌ខ្មែរនាសម័យបុរេប្រវត្តិ គេក៏បានប្រើស្គរទាំងនោះសម្រាប់ផ្ទុកអដ្ឋិធាតុដែរ។

---

(៥) មីសែល ត្រាណេ ៖ **៥.០០០ឆ្នាំនៃទំនាក់ទំនងខ្មែរ-ចិន នៅក្នុងសន្និសីទអន្តរជាតិលើកទី១ ស្តីពីទំនាក់ទំនងកម្ពុជា-ចិននាសម័យចេនឡានិងអង្គរ**, រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១ ទំព័រទី៧៥-៧៧។

**ស្គរមហោរធឹក** ឬ ស្គរហៅទឹកភ្លៀងជាប្រភេទស្គរម្យ៉ាងធ្វើអំពីសំរិទ្ធភាគច្រើនមានទ្រង់ទ្រាយធំ ហើយមានដៃព្យួរសម្រាប់ទូងក្នុងពិធីបុណ្យសាសនាផ្សេងៗ ជាពិសេសដើម្បីសុំទឹកភ្លៀង ឬពរជ័យសិរីមង្គលពីកម្លាំងធម្មជាតិ ឬព្រលឹងដូនតា។ ស្គរនេះស្ថិតក្នុងសម័យកាលចុងសម័យសំរិទ្ធ និងដើមសម័យប្រវត្តិសាស្រ្ត។

យើងអាចសន្និដ្ឋានបានថា ស្គរមហោរធឹកសំរិទ្ធដែលគេទូងក្នុងពិធីបុណ្យសុំទឹកភ្លៀងពិតជាវត្ថុបង្កប់លក្ខណៈដ៏ពិសិដ្ឋអស្ចារ្យក្នុង <u>ក្រសែភ្នែករបស់កសិករចិនបុរាណ</u>។ តាមពិតទៅចំពោះមនុស្សបុរាណក៏ដូចបច្ចុប្បន្នភាពដែរ កើតមកក្នុងលោកយើងនេះគ្មានអ្វីសំខាន់ជាងស្រូវ អង្ករ និងទឹកដែលជាប្រភពនៃជីវិត។

យើងត្រូវកត់សម្គាល់ទៀតថា **ស្គរមហោរធឹក** មិនមែនជាស្គរធម្មតានោះទេ ប៉ុន្តែជាឧបករណ៍ស័ក្តិសិទ្ធបំផុតមួយប្រភេទ ដែលគេប្រើក្នុងពិធីសុំទឹកភ្លៀង ដោយសហគមន៍មនុស្សនាសម័យដើម ដើម្បីដាស់សតិព្រលឹងធម្មជាតិទៅតាមសូរសៀងសំឡេងដែលគេទូងម្តងប្រយោជន៍ឱ្យជីវិតប្រកបដោយភាពត្រជាក់ត្រជុំផ្សូរផង់ចម្រុងចម្រើនលូតលាស់ តាមរយៈតំណក់ទឹកភ្លៀង។

ដូចនេះយើងអាចបញ្ជាក់អំពីអត្ថន័យស្គរថា **ស្គរមហោរធឹកសំរិទ្ធ** ដែលមានឥទ្ធិពលទៅលើចិត្តសាស្រ្តសង្គមគ្រួសារចិនយ៉ាងខ្លាំងក្លាពីព្រោះវាមានការពាក់ព័ន្ធទៅនឹងទម្រង់សង្គមនៃរបៀបរស់នៅរបស់មនុស្សបុរាណយ៉ាងប្រាកដ។ នេះជាការសន្និដ្ឋានយ៉ាងត្រឹមត្រូវសម្រាប់ជនជាតិ និងកុលសម្ព័ន្ធចិនគ្រប់សម័យកាល។ តែយើងមិនអាចធ្វើការសន្និដ្ឋាននេះក្លាយជាសច្ចភាព ក្នុងសង្គមខ្មែរចុងសម័យសំរិទ្ធឡើយក្នុងខណៈដែលគេប្រើស្គរទាំងនោះ សម្រាប់ដាក់ឆ្អឹងមនុស្ស។

តែទោះបីជា **ស្គរមហោរធឹកសំរិទ្ធ** មានប្រភពចេញពីចិនមុនការផ្សព្វផ្សាយទៅលើហ្វូណន ចម្ប៉ា ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងភូមាយ៉ាងណាក៏ដោយ ក៏វត្តមានរបស់ឧបករណ៍ភ្លេងនោះមានប្រយោជន៍ខ្លាំងណាស់ សម្រាប់ប្រវត្តិសាស្រ្តនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន។ ស្គរនេះអាចធ្វើឱ្យយើងស្គាល់ប្រព័ន្ធជំនឿបែបជីវចលនិយម ស្តីពីលោកធាតុនិយម ដែលជាតម្រូវការកំពូលរបស់មនុស្សក្នុងសង្គម និងអាចបង្ហាញបញ្ជាក់ពីទំនាក់ទំនងយ៉ាងជិតស្និទ្ធខាងវប្បធម៌ និងបច្ចេកទេសរវាងបុព្វការីជនរបស់ជនជាតិខ្មែរយើងជាមួយជនជាតិចិនយ៉ាងប្រត្យក្ស។ ដោយឡែកខាងបច្ចេកទេសដើម្បីផលិតស្គរទាំងនោះ <u>គឺកើតចេញពីមូលហេតុពាណិជ្ជកម្មរវាងប្រទេសយើងទាំងពីរ កម្ពុជា-ចិន មុនការបង្កើតរដ្ឋហ្វូណនមកម្លេះ</u>។

### ខ-ស្គរមហោរធឹកថ្មីមួយនៅស្រុកវ៉ារិន សៀមរាប

ដោយឡែកមានភស្តុតាងថ្មីមួយបង្ហាញឱ្យឃើញថា ខេត្តសៀមរាបកាលពី២.០០០ឆ្នាំកន្លងមកនេះក៏ធ្លាប់មានទំនាក់ទំនងដោយត្រង់ឬដោយប្រយោលជាមួយជនជាតិចិន ព្រោះគេបានរកឃើញ **ស្គរមហោរធឹកសំរិទ្ធ** នេះនៅបុរាណស្ថានក្នុងស្រុកវ៉ារិន ខេត្តសៀមរាបកាលពីឆ្នាំ២០០៤ នូវស្គរនាសម័យប្រវត្តិសាស្រ្ត មានទំហំ៦២សង់ទីម៉ែត្រគុណនឹង៧៥សង់ទីម៉ែត្រ។ វត្តមានរបស់ស្គរនេះនៅលើទឹកដីដ៏បវរនៃខេត្តសៀមរាប ជាវត្ថុតាងខាងប្រវត្តិសាស្រ្តមួយយ៉ាងសំខាន់ ព្រោះវាបង្ហាញទំនាក់ទំនងខាងពាណិជ្ជកម្មរវាងប្រទេសមួយចំនួនក្នុងតំបន់និងមហាប្រទេសចិនដែលជាទឹកដីកំណើតនៃ **ស្គរមហោរធឹកសំរិទ្ធ** ទាំងនោះ។ បច្ចុប្បន្នស្គរនេះបានយកទៅតម្កល់នៅអភិរក្សដ្ឋានអង្គរ ក្រុងសៀមរាប។ ដោយឡែកនៅសារមន្ទីរជាតិនៃទីក្រុងភ្នំពេញ **ស្គរមហោរធឹកសំរិទ្ធ** មានចំនួន៤ទៀត។

### ១.២.២-សិប្បកម្មមាស

បើនិយាយពីការវិវត្តផ្នែកវប្បធម៌ក្នុងចុងយុគលោហៈ ក្នុងចំណោមសមិទ្ធផលសង្គមគួរឱ្យចាប់អារម្មណ៍ជាងគេ គឺការផលិតគ្រឿងអលង្ការធ្វើអំពីមាស សំរិទ្ធ និងប្រាក់ និងជាអ្វីមួយដែលអ្នកកាលប្បវត្តិចិនបានគូសបញ្ជាក់ដើមសតវត្សទី១នៃគ្រិស្តសករាជយ៉ាងប្រត្យក្ស។ យើងបានដឹងថានៅភូមិព្រៃក្មេង, ភូមិស្នាយ, ភូមិស្វាយចេក, ភូមិព្រហារ (ខេត្តព្រៃវែង), គោកអូរជួ និងនៅទួលយ៉ុងកាវ៉ូក្នុងទឹកដីកម្ពុជាក្រោម ធ្វើឱ្យយើងចាប់ផ្តើមមើលឃើញចំណុចជាវិជ្ជមានមួយចំនួន ដែលបានកើតឡើងមុនសម័យប្រវត្តិសាស្រ្តបន្តិចដែលជាកត្តាប្រាប់ឱ្យដឹងអំពី **«ឫសកែវ»** នៃសិប្បកម្មមាសដែលបានកើតឡើង។

ក្នុងដំណាក់កាលដំបូង ជនជាតិខ្មែរអាចនាំចូលបច្ចេកទេសផលិតពីចិន ហើយក្រោយមកផលិតដោយខ្លួនឯងផ្ទាល់។ ការណ៍នេះ ដោយសារស្ថានភាព វប្បធម៌និងភូមិសាស្រ្តតម្រូវឱ្យខ្មែរនិងចិនមានសម្ព័ន្ធភាព យ៉ាងជិតស្និទ្ធក្នុងតំបន់ ហើយវាជារឿងធម្មតា។ តែទោះជាយ៉ាងនេះក៏ដោយ ក៏គេត្រូវទទួលស្គាល់ថាជនជាតិខ្មែរនាសម័យនោះប្រកបដោយទេពកោសល្យខ្ពស់មិនមែនមិនទាន់ចេះប្រើលោហធាតុនោះទេ។

សិប្បករខ្មែរមានគំនិតច្នៃប្រឌិតខ្ពស់ក្នុងការផលិតកងដៃ ក្រវិលត្រចៀក ចិញ្ចៀន និងបន្តោងខ្សែកជាដើម បានរួមចំណែកធ្វើឱ្យប្រទេសកម្ពុជាបានក្លាយទៅជាមហាអំណាចមួយដ៏មានឥទ្ធិពល នៅក្នុងសម័យហ្វូណននៅអាស៊ីអាគ្នេយ៍។ ប៉ុន្តែទោះជាយ៉ាងណា ក៏យើងត្រូវទទួល



សម្ភារៈធ្វើអំពីមាស-ប្រាក់ (នៅស្ថានីយព្រហារ)
(ប្រភព ៖ Andreas Reinecke, Vin Laychour, Seng Sonetra)

ស្គាល់ថាផ្នែកមួយប្រពៃណីវប្បធម៌នៃជនជាតិចិននិងឥណ្ឌាបានរួមចំណែកដល់ខឿនប្រពៃណីវប្បធម៌ជនជាតិខ្មែរ។

គួរបញ្ជាក់ផងដែរថា ឥទ្ធិពលនៃវត្ថុមាន **ស្គរមហោរធឹក** អាចជាសញ្ញាវិជ្ជមានបង្ហាញពីទំនាក់ទំនងរវាងខ្មែរនិងចិន រវាងសតវត្សទី៣ មុនគ្រិស្តសករាជ។ ក្នុងប្រទេសចិន ជាពិសេសក្នុងសន្តតិវង្ស **សៀ** ប្រមាណជា៣.០០០ឆ្នាំមុនគ្រិស្តសករាជ បច្ចេកទេសស្លមាសត្រូវបានផ្តើមឡើងមុនគេបង្អស់។

តាមការវិភាគរកកាលបរិច្ឆេទដោយប្រើបច្ចេកទេសវិទ្យុសកម្មកាបូន១៤ ធ្វើឲ្យយើងដឹងថាសិប្បកម្មមាសក្នុងដែនកម្ពុជាយើងត្រូវបានផ្តើមឡើងរវាង២៥០ឆ្នាំមុនគ្រិស្តសករាជរហូតដល់សតវត្សទី៣ និងទី៤នៃគ្រិស្តសករាជប៉ុណ្ណោះ។ ដោយភាពស្រដៀងគ្នានេះ ក៏ត្រូវបានជួបប្រទះនៅប្រទេសអឺរ៉ុបមួយចំនួនដែរមុនឥទ្ធិពលរបស់ពួករ៉ូម៉ាំង។

កត្តាចម្បងមួយទៀតដែលជាមូលដ្ឋានសម្រាប់ការវាយតម្លៃឱ្យបានត្រឹមត្រូវនូវសារៈសំខាន់នៃខឿនវប្បធម៌របស់អ្នកស្រុកខ្មែរយើង បានឱ្យដឹងទៀតថាភាពខុសគ្នារវាងគ្រឿងអលង្ការខ្មែរនិងចិន ឬឥណ្ឌា។ តាមពិតទៅ ទោះបីមានឥទ្ធិពលបច្ចេកទេសមកពីក្រៅក៏ដោយ

ក៏ប៉ុន្តែក្បូរក្បាច់រចនានៃគ្រឿងអលង្ការបុរាណទាំងនោះមានលក្ខណៈខុសគ្នាដែលគួរឱ្យចាប់អារម្មណ៍។ លក្ខណៈខុសគ្នានៃការតុបតែងដ៏សម្បូរបែបនៃសិល្បៈដែលជាផ្នែកមួយសម្រាប់សម្គាល់ប្រវត្តិតំបន់និងជាតិសាសន៍ អាចជាកត្តាសម្រាប់កំណត់ភាពមិនឯកភាពគ្នា។ បើយើងពិនិត្យវត្ថុសិល្បៈចិន ឥណ្ឌា និងខ្មែរ ឬបើដាក់ផ្ទឹមគ្នា ទោះបីបច្ចេកទេសផលិតមួយចំនួនបានទទួលឥទ្ធិពលចិន និងឥណ្ឌាដែលមានវត្តមានក្នុងតំបន់នេះដ៏យូរលង់យ៉ាងណាក៏ដោយ ក៏យើងឃើញថាមានអ្វីមួយ ដែលហាក់ដូចជាបង្ហាញយើងឱ្យដឹងថាសិប្បកម្មប្រពៃណីនៅស្វាយ, ស្វាយចេក ឬនៅព្រហារ ឬក៏នៅតំបន់ផ្សេងៗ **មិនបានកើតចេញពីឫសគល់រួមតែមួយជាមួយចិននោះទេ**[៦]។

ទាំងអស់ខាងលើនេះ វាបានឆ្លុះបញ្ចាំងឱ្យឃើញអត្តសញ្ញាណនិងនិរន្តរភាពនៃមរតកវប្បធម៌ខ្មែរបុរាណ។ ដូចគ្នានឹងទស្សនៈស្តីពីការផលិត ជនជាតិចិនឬឥណ្ឌា គ្រឿងអលង្ការខ្មែរបុរាណទាំងនោះសម្តែងអារម្មណ៍និងស្មារតី ពោលគឺមនោសញ្ចេតនារបស់ប្រជាជាតិខ្មែរ។ យ៉ាងណាមិញ យើងក៏មិនត្រូវភ្លេចផងដែរថានៅក្នុងដែនដីខ្មែរមានរ៉ែមាស ជាវត្ថុធាតុដើមចាំបាច់បំផុត សម្រាប់ផលិតគ្រឿងលម្អសំខាន់ៗដល់មនុស្សទូទៅ។

គ្រឿងអលង្ការមួយចំនួន ដូចជា ក្រវិលត្រចៀកដែលគេបានរកឃើញនៅស្ថានីយស្វាយ ក៏ដូចនៅស្ថានីយមួយចំនួនទៀតដូចជាស្ថានីយស្វាយចេកក្នុងនៅខេត្តឧត្តរមានជ័យនិងស្ថានីយកោះគោកតាមាសនៅសៀមរាប ដែលភាគច្រើនសុទ្ធសឹងតែការផ្សំធាតុលោហៈមួយចំនួនដូចជាសំណ, សំរិទ្ធ, ប្រាក់, ហើយស្រោបមាសពីខាងក្រៅ រីឯគ្រឿងអលង្ការខ្លះទៀតមានលាយស្ពាន់ជាមួយផងដែរ។ យោងតាមទិន្នន័យនេះ យើងអាចកត់សម្គាល់ថាមាសដែលជាវត្ថុធាតុមានសាច់ទន់ស្វិត ហើយមានពណ៌លឿងត្រូវបានបុព្វការីជនខ្មែរផលិតដើម្បីធ្វើជាគ្រឿងអលង្ការតាំងពី២.០០០ឆ្នាំមកហើយ។ ការប្រើគ្រឿងអលង្ការធ្វើអំពីមាស ឬស្រោបមាសនៅភូមិស្វាយ ដែលត្រូវបាន គេផ្តើមឡើងនៅដើមសម័យប្រវត្តិសាស្ត្រ ពោលគឺរវាងសតវត្សទី១ ដល់ទី៤ គឺជាសក្ខីកម្មស្រាប់។ នេះគឺជាលទ្ធផលនៃការស្រាវជ្រាវខាងបុរាណវិទ្យាដែលជាកត្តាមួយយ៉ាងសំខាន់ សម្រាប់ការកំណត់កាលបរិច្ឆេទនៃវប្បធម៌នៅភូមិស្វាយផង។ វាមានលក្ខណៈស្រដៀងនឹងស្ថានីយមួយចំនួនទៀតក្នុងភូមិភាគនេះ ក៏ប៉ុន្តែ យើងនៅរង់ចាំការស្រាវជ្រាវបន្ថែមមួយចំនួនទៀតមុននឹងឈានទៅរកទិដ្ឋភាពរួម ឬសំយោគមួយដែលជាវត្ថុប៉ង

---

(៦) www.cen.com.kh/Culture

ប្រាថ្នារបស់យើង។

បើតាមការពិនិត្យខ្លឹមសារនៃសំណេរ សរសេរដោយដៃនៃជនជាតិចិន មានតាំងតែពី ១០០ឆ្នាំមុនគ្រិស្តសករាជនោះ បានផ្តល់ឱកាសឱ្យខ្មែរយើងពិចារណាឡើងវិញអំពីចំណាស់នៃទំនាក់ទំនងមិនគ្រាន់តែរវាងចិននិងឥណ្ឌាប៉ុណ្ណោះទេ ក៏ប៉ុន្តែរវាងចិននិងខ្មែរ ឬខ្មែរនិងឥណ្ឌាផងដែរដែលមានការប្រាស្រ័យទាក់ទងរកគ្នាដោយមូលហេតុផ្សេងៗយ៉ាងប្រាកដ។ គួរបញ្ជាក់ផងដែរថាតាមរយៈវត្ថុបុរាណចិនមួយចំនួនដែលគេបានជួបប្រទះនៅតាមស្ថានីយប្រវត្តិសាស្ត្រមួយចំនួនក្នុងឧបទ្វីបឥណ្ឌូចិនគួបផ្សំទៅនឹងសំណេរទាំងនោះ គេអាចបញ្ជាក់បានទំនាក់ទំនងរវាងជនជាតិចិន-ខ្មែរខាងលើនេះដែរ។ តាំងពីដើមរៀងមក ទំនាក់ទំនងនេះមានលក្ខណៈសេដ្ឋកិច្ចច្រើនជាងនយោបាយ ហេតុដែលយើងមានការចាប់អារម្មណ៍លើស្លាកស្នាមវប្បធម៌បុរាណចិន គឺដោយសារតែចំណុចនេះមិនសូវត្រូវបានគេលើកយកមកនិយាយ ហើយជាអ្វីមួយដែលពុំបានចែង ឬអធិប្បាយក្នុងសៀវភៅប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាឡើយ។ម្យ៉ាងទៀត យើងក៏ត្រូវជ្រាបផងដែរថាការកត់ត្រាព្រឹត្តិការណ៍ផ្សេងៗដោយចិន ដែលជាមូលដ្ឋានគ្រឹះនៃប្រវត្តិសាស្ត្រខ្មែរ មិនផ្ទុយទៅនឹងទិន្នន័យខាងបុរាណវិទ្យាទេ។ យើងចង់បញ្ជាក់ឱ្យឃើញអំពីសេចក្តីសំខាន់របស់វត្ថុបុរាណទាំងនោះ ក្នុងការចងក្រងប្រវត្តិសាស្ត្រខ្មែរតែប៉ុណ្ណោះជាពិសេសកញ្ចក់ឆ្លុះមុខក្នុង **រាជវង្សហាន** (២០០មុនគ្រិស្តសករាជ -១២០នៃគ្រិស្តសករាជ) និង **រាជវង្សថាំង** (៦១៨នៃគ្រិស្តសករាជ-៩០៧នៃគ្រិស្តសករាជ) ព្រមទាំងព្រះពុទ្ធបដិមាចិនក្នុង **រាជវង្សសួយ** (៥៨១នៃគ្រិស្តសករាជ-៦១៨នៃគ្រិស្តសករាជ) ជាដើម។

ព្រះរាជាណាចក្រកម្ពុជាដែលមានទំនាក់ទំនងជាមួយចិនមានជាង២.០០០ឆ្នាំមកហើយនោះ ត្រូវបានអ្នកស្រាវជ្រាវ **ល្វីម៉ាល្លើរ** (ជនជាតិបារាំង) ដែលបានសិក្សាវិភាគហើយធ្វើសន្និដ្ឋានថាប្រទេសនេះមានភាពរុងរឿងរីកចម្រើន គឺមកពីជនជាតិនេះបានធ្វើជំនួញជាមួយចិន តែជនជាតិខ្មែរមិនសូវប្រសប់ ក្នុងការធ្វើពាណិជ្ជកម្មទេ។ ប៉ុន្តែ ការយល់ឃើញទាំងនេះសមរម្យហើយ តែមិនទាន់ត្រឹមត្រូវទាំងស្រុងទេ ព្រោះថាទន្ទឹមនឹងការធ្វើជំនួញជាមួយចិនជនជាតិខ្មែរបានធ្វើជំនួញជាមួយនឹងជនជាតិបរទេសនានា ជាពិសេសជនជាតិឥណ្ឌាដែលជាប្រភពនាំឱ្យលេចធ្លោឡើងនៃប្រទេស **ហ្វូណន**។

## ជំពូក២

# សម័យហ្វូណន - រាជ្យព្រះស្តេចកន

តាំងពីបុរាណកាលរៀងរហូតមក ជនជាតិចិនបានទទួលស្គាល់ឈ្មោះរបស់ប្រទេសកម្ពុជាតែ៣ប៉ុណ្ណោះ គឺ ទី១-ហ្វូណន ទី២-ចេនឡា និងទី៣-កាំប៉ូវជេ (ភាសាចិនទាជីវអានពាក្យ **«កម្ពុជា»**) ឬ ជានភូចៃ (ភាសាហាន)។ ហ្វូណន គឺសំដៅសម័យដើមនៃប្រវត្តិសាស្ត្រខ្មែរ។ ចេនឡា គឺជាសម័យកាលបន្តពីហ្វូណន។ កាំប៉ូវជេ ឬ ជានភូចៃ ជាសម័យកាលក្រោយសតវត្សទី១៥។ ហេតុនេះទើបលោក **ជីវតាក្វាន់** មកកាន់កម្ពុជានាសម័យអង្គរ ក៏គាត់នៅតែប្រើបញ្ញត្តិ **«ចេនឡា»** សម្គាល់ប្រទេសកម្ពុជានាសម័យនោះដែរ។




ផែនទីខ្មែរនាសម័យហ្វូណន

(ប្រភព ៖ បណ្ឌិត មីសែល ត្រាណេ)




ភូមិសាស្ត្រកំពង់ផែអូរកែវនាពេលបច្ចុប្បន្ន
(ប្រភព ៖ Andreas Reinecke , Vin Laychour, Seng Sonetra)

**ហ្វូណន** គឺជាពាក្យដែលជនជាតិចិនកំណត់សម្គាល់រដ្ឋខ្មែរដំបូងបង្អស់។ ពាក្យ **«ហ្វូណន»** នេះ ត្រូវបានកត់ត្រានៅក្នុងឯកសារចិន ហើយរហូតដល់សព្វថ្ងៃនេះ កំណត់ត្រារបស់ចិនក្លាយជាឯកសារគោលឬឯកសារយោង សម្រាប់ពិពណ៌នាអំពីប្រទេសកម្ពុជា នាដើមសតវត្សទី១ដែលខ្មែរបានប្រសិទ្ធនាមថា **«នគរភ្នំ»**។ ការកំណត់យកពាក្យ **ហ្វូណន** ត្រូវនឹងពាក្យ **នគរភ្នំ** នេះ គឺតាមសម្មតិកម្មរបស់លោក Gorges Coedès ដែលបានអះអាងថា ហ្វូណន ត្រូវនឹងពាក្យខ្មែរបុរាណ **វ្នំ** ដែលសព្វថ្ងៃក្លាយជា **ភ្នំ** ។ បើតាមសម្មតិកម្មនេះ យើងយល់ឃើញថា មានលក្ខណៈមិនសមស្រប ព្រោះពាក្យ **ហ្វូណន** ជនជាតិចិន បច្ចុប្បន្នបានសរសេរជាភាសាចិនថា 扶南( 扶= ជួយ ឬគ្រាអ្នកដទៃ និង 南= ទិសខាងត្បូង ) មានន័យថាប្រទេសខ្មែរដែលនៅភាគខាងត្បូងរបស់ប្រទេសចិនជាប្រទេសដែលជួយដល់ប្រទេសដទៃទៀត។ តើខ្មែរអាចជួយប្រទេសដទៃដោយរបៀបណា? នេះក៏ជាការបង្កប់ន័យថា ប្រទេសខ្មែរជាប្រទេសអ្នកមាន។ ហេតុនេះបើតាមភាសាចិន គួរសរសេរ **ហ្វូណន** ជា 富 南 ( 富 =មានទ្រព្យ និង

ណ៏=ទិសខាងត្បូង ) ដែលអាចមានន័យថាជាប្រទេស ឬជាជនជាតិដែលមានទ្រព្យសម្បត្តិនៅភាគខាងត្បូងប្រទេសចិន ព្រោះហ្វូណានមានកំពង់ផែអូរកែវដែលមានទីតាំងនៅក្នុងសមុទ្រចិនខាងត្បូងដែលជាកំពង់ផែដ៏មានសក្តានុពលខ្លាំងក្លាបំផុត នៅអាស៊ីអាគ្នេយ៍នាពេលនោះ។ ការកំណត់យកប្រទេសកម្ពុជាគឺជាប្រទេសអ្នកមានមួយនៅភាគខាងត្បូងរបស់ប្រទេសចិននោះគឺជាការសមស្របណាស់ ព្រោះនៅសតវត្សទី២ អ្នកភូមិសាស្ត្រក្រិកឈ្មោះ Ptoémée បានសរសេរសៀវភៅភូមិសាស្ត្រដែលមានវគ្គមួយនិយាយពីភូមិភាគអាស៊ីអាគ្នេយ៍ដីគោក និងដីកោះ (ដែលរួមមានហ្វូណាន)។ អ្នកស្វែងរកមាសឱ្យឈ្មោះភូមិភាគនេះថា **សុវណ្ណភូមិ** (សម្គាល់ដីគោក) និង **សុវណ្ណទ្វីប** (សម្គាល់ដីកោះ) គឺត្រូវនឹងពាក្យ La Chrysé និង La Chersonèse ។ ដោយឡែក យោងតាមកំណត់ហេតុចិនបានឱ្យដឹងថារវាងឆ្នាំ២២០និង២៣០ ហ្វូណានដឹកនាំដោយព្រះបាទ ហ្វាន់ ស៊ីម៉ាន់ ឬ ហ្វាន់ ចេម៉ាន់ ដែលជាឧត្តមសេនីយ៍ម្នាក់ដ៏ខ្លាំងពូកែ ហើយទទួលបានគោរម្យងារជាស្តេចក្នុងឋានៈជាឧត្តមសេនីយ៍នៃសមុទ្រខាងត្បូង ។

ដោយឡែកបញ្ញត្តិ **ចេនឡា** ត្រូវបានលោក **លី ធាមតេង** បានពន្យល់ថាកាលពីដើមឡើយចិនបានហៅរដ្ឋចំណុះមួយរបស់ហ្វូណានថាចេនឡា (ចេន =សុទ្ធ និង ឡា = ក្រមួន)។ រដ្ឋនេះមានព្រៃក្រាស់ណាស់ហើយសំបូរឃ្មុំយកក្រមួនធ្វើទៀន។ ជនជាតិចិនតែងធ្វើដំណើរមកទិញដូរយកក្រមួនសុទ្ធពីរដ្ឋនេះ។

## ២.១-វប្បធម៌

### ២.១.១-ក្រមាខ្មែរ

គួរបញ្ជាក់ផងដែរថាប្រទេសចិននាសម័យនោះគឺសម័យសាមកុក ដែលមាន **នគរវៃ នគរស៊ូ** និង **នគរវូ** ។ **នគរវូ** ដែលមានមេដឹកនាំឈ្មោះ **ស៊ុនឈាន** បានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះបេសកជនពិសេសរបស់កម្ពុជាដែលបានមកទស្សនកិច្ចនៅប្រទេសចិន ហើយ **ស៊ុនឈាន** បានចាត់មន្ត្រីជាន់ខ្ពស់ពីររូបគឺ **ជូយីង** និង **កាំងថៃ** មកទស្សនកិច្ចនៅប្រទេសកម្ពុជា។ ឯកសារប្រវត្តិសាស្ត្រកម្ពុជាបានបញ្ជាក់ថាលោក **កាំងថៃ** ដែលជារាជទូតចិនបានធ្វើដំណើរមកហ្វូណាន នៅពាក់កណ្តាលសតវត្សទី៣[៧]។ បេសកជនចិននេះបានទទួល

---

(៧) ខ្លួត ធីតា ៖ **ទស្សនវិជ្ជាខ្មែរសម័យបុរេប្រវត្តិដល់សម័យចេនឡា នៅក្នុងសន្និសីទអន្តរជាតិលើកទី១ ស្តីពីទំនាក់ទំនងកម្ពុជា-ចិននាសម័យចេនឡានិងអង្គរ**, រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១។

ស្វាគមន៍យ៉ាងកក់ក្ដៅពីព្រះរាជាខ្មែរ ដោយបានផ្ដល់ **ក្រមា** ដល់បេសកជនចិនទាំងពីរទទួរ ដោយសារតែអាកាសធាតុនាពេលនោះក្ដៅជាងអាកាសធាតុនៅប្រទេសចិន។ នេះជាការលើកយកបញ្ញត្តិ «**ក្រមា**» មកពិពណ៌នាមុនគេ នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាដែលត្រូវបានកត់ទុកដោយបេសកជនចិនទាំងពីររូបនោះ។ ចាប់ពីឆ្នាំ២២៥ដល់ឆ្នាំ៥៣៩ ប្រទេសកម្ពុជានៅសម័យហ្វូណនបានចាត់បេសកជនរបស់ខ្លួន១០ដងទៅ ប្រទេសចិន ដើម្បីរឹតចំណងមិត្តភាពរវាងប្រទេសយើងទាំងពីរ។

គួរបញ្ជាក់ថា **ក្រមា** ជាវត្ថុដ៏មានតម្លៃនៅក្នុងវប្បធម៌ខ្មែរ ដូចមានក្នុងអត្ថន័យកំណាព្យខាងក្រោម ៖



- នេះនឹងថ្លាថ្លែងចែងចរចា ស្ដីពីក្រមាសូត្រអំបោះ
  ក្រឡាចត្រង្គពណ៌ល្អស្រស់ កូនខ្មែរស្រណោះគេងអង្រឹង ។
- កូនប្រុសកូនស្រីលេងជាក្រុម ធ្វើកូនក្រមុំក្រមាហ្នឹង
  ពេលងូតទឹកស្រះអូរឬស្ទឹង ពុកម៉ែស្ទុះរឹងយកមកផ្លាស់ ។
- ផលពីក្រមាប្រើគ្រប់សព្វ បក់មូសដណ្ដប់ប្រពៃណាស់
  ប្រើបានទាំងក្មេងបានទាំងចាស់ ជូនជាពកប៉ះផ្សះផ្ដុំស្ពំ ។
- នារីផ្លាស់អាវតែងចោមពុង ស្រីស្រស់នោមយង់ទ្រង់ស័ក្ដិសម
  ការកេរ្តិ៍ជាស្រីស្រស់ឧត្ដម ពេលការងារខំជាឈ្នួតក្បាល ។
- ថ្ងៃក្ដៅម្ដេចក្ដីយើងទទួរ ដើរឆាប់ដើរយូរល្អគ្រកាល
  ពេលខ្លះស្រីទូលធ្ងន់ឬស្រាល ក្រមាទ្រាប់ក្បាលជារង្វេល ។
- ជូនជាសម្រាន្តប្រាណជាប់ក្ការ យើងក្រាលក្រមាជាកន្ទេល
  ខ្វះខ្នើយបត់កើយគេងលក់រេល ប្រើបានគ្រប់ពេលគ្មានខ្វល់អ្វី ។
- ពេលក្មេងតូចធំជុំអ៊ូអរ បាយឡុកបាយឡទាំងប្រុសស្រី
  ក្រមាត្រកួញធ្វើខ្សែតី ប្រមោយដំរីលេងសប្បាយ ។
- ក្រមាធ្វើឈ្យូងលាក់កន្សែង លេងចាប់កូនខ្លែងសើចក្អាកក្អាយ

ពេលណាងូតទឹកហែលជិតឆ្ងាយ ក្រមាបានក្លាយពោងអណ្តែត ។
- ចងក្បិនក្រមាឡើងដើមឈើ ដូងត្នោតលូតលើខ្ពស់រាប់ម៉ែត្រ
ក្រមាប្រើបានទាំងក្រុងខេត្ត ប្រយោជន៍ហួសហេតុថ្លៃងពុំបាន ។
- បត់ចងធ្វើអាវឱ្យកូនចៅ ពេលណាស្អុះក្តៅអស់អង្គប្រាណ
បក់ជំនួសផ្លិតយ៉ាងចំណាន នៅគ្រប់សន្តានខ្មែរតែងប្រើ ។
- ចងជាទន្លីងឡើងដូងត្នោត ទាបខ្ពស់ម្តេចសោតសឹងប្រសើរ
ជៀសវាងគ្រោះថ្នាក់បានគ្រាន់បើ ដល់ដីចុះដើរយកបង់ក ។
- ទម្លាប់ខ្មែរយើងមកយូរយារ ចូលវត្តពានាស្រស់បវរ
ទាំងក្រមាសូត្រអំបោះស កូនចៅប្រើតជៅសន្តាន ។
- ចង្កេះបុរសចងក្រមា ងាយធ្វើកិច្ចការជុំវិញប្រាណ
មិនទើសមិនទាស់នាំរំខាន ការងារប៉ុន្មានតែងបានផល ។
- គំនូរចម្លាក់ឆ្លាក់ឈើថ្ម ញើសហូរម្តេចក៏មិនអែកអល់
ក្រមាជូតញើសគ្មានសេសសល់ កូនខ្មែរមិនខ្វល់ទុកជាប់ប្រាណ ។
- ក្រមាចងថ្នក់ដក់បន្លែ អ្នកចម្ការស្រែមិនដែលខាន
ចងថ្នក់ជាយពីរម្ខាងតាមបាន ទម្លាប់សន្តានដូចគ្នាដែរ ។
- ថ្ងៃមានកម្តៅក្តៅចែងចាំង ក្រមាចងបាំងឱ្យមាសស្នេហ៍
បានម្លប់ឱ្យកូនទាំងពុកម៉ែ ធ្វើចម្ការស្រែតាមត្រូវការ ។
- ពេលធ្វើដំណើរដើរស្រុកឆ្ងាយ សម្ពាយជាប់កាយទាំងយាយតា
ខោអាវសំពត់វេចក្រមា ជារឿងធម្មតាតាមក្រមាន ។
- ពេលដាច់សង្វែងចូលព្រៃជ្រៅ គ្មានឆ្នាំងជាប់ទៅពេលពោះឃ្លាន
ក្រមាដាំបាយបានត្រូវរៀន ក្រមាធនធានខ្មែរប្រពៃ[៨]៕

---

(៨) វ៉ឺន សុន ៖ **កំណាព្យក្រមាខ្មែរ** ភ្នំពេញ ឆ្នាំ២០០៩ (បោះពុម្ពលើកទី២)។







ផែនទីប្រទេសចិនសម័យសាមកុក

( ប្រភព ៖ www.thethreekingdoms.wikia.com )

### ២.១.២-ពុទ្ធបដិមា

ប្រវត្តិសាស្ត្រនៃព្រះពុទ្ធសាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជាមានចំណាស់ស្មើនឹងប្រវត្តិសាស្ត្រខ្មែរ។ តាមពិត ព្រះពុទ្ធសាសនាដែលបានចាក់ឫសយ៉ាងជ្រៅក្នុងទឹកដីខ្មែរតាំងពីដើមសតវត្សទី១ មិនដែលសាបសូន្យម្តងណាឡើយ គ្រាន់តែកាលខ្លះមិនលេចធ្លោជាផ្លូវការតែប៉ុណ្ណោះ។

តាមកំណត់ហេតុនៃ **រាជវង្សលាង** (៥០២-៥៥៦នៃគ្រិស្តសករាជ) ព្រះមហាក្សត្រហ្វូណនបានបញ្ជូនរាជទូតខ្មែរម្នាក់ទៅកាន់ប្រទេសចិន ដើម្បីថ្វាយជំនូនមួយដែលគេច្រឡំថាជាស្បូយសារអាកររបស់ស្រុកចំណុះរួមមានបដិមាព្រះពុទ្ធធ្វើអំពីផ្កាថ្ម។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ នេះបានប្រព្រឹត្តឡើងនៅឆ្នាំ៥០៣។ គេក៏បានដឹងដែរថាមានព្រះសង្ឃខ្មែរពីរព្រះអង្គទៀតនៃចក្រភពភ្នំបាននិមន្តទៅកាន់ប្រទេសចិនដើម្បីប្រែគម្ពីព្រះត្រៃបិដកចិន គឺព្រះភិក្ខុ **សិង្ហបាល** និង មន្ទ្រីសាសនា។ ព្រះភិក្ខុសង្ឃទាំងពីរអង្គនេះមានបេសកកម្មដ៏ឧត្តុង្គឧត្តមមួយគឺការប្រែគម្ពីរព្រះត្រៃបិដកពីភាសាសំស្ក្រឹតទៅជាភាសាចិន។

តាមប្រវត្តិសាស្ត្រនៃ **រាជវង្សលាង** ដដែល យើងក៏បានដឹងទៀតថា ព្រះបាទ **រុទ្រវរ្ម័ន** នៃចក្រភពនគរភ្នំសុទ្ធសឹងតែកាន់ព្រះពុទ្ធសាសនា។ ដូច្នេះហើយក្នុងរាជបំណាងពង្រឹងមេត្រីភាព

រវាងជនជាតិខ្មែរ និងចិនដែលប្រកាន់លទ្ធិព្រះពុទ្ធសាសនាដូចគ្នា ព្រះបាទ **រុទ្រវរ្ម័ន** បានបញ្ជូនរាជទូតខ្មែរទៅកាន់ប្រទេសចិននៅឆ្នាំ៥១៩ ដោយមានតង្វាយទៅព្រះចៅក្រុងចិននូវចម្លាក់ព្រះពុទ្ធរូបធ្វើអំពីឈើខ្លឹមច័ន្ទក្រស្នា។ ហើយ២០ឆ្នាំក្រោយពោលគឺនៅឆ្នាំ៥៣៩ ព្រះមហាក្សត្រិយ៍ដដែលបានផ្ញើថ្វាយរូបព្រះពុទ្ធមួយព្រះអង្គទៀតទៅកាន់ព្រះមហាក្សត្រចិន ដែលមានកម្ពស់១២ហ្វីត ហើយព្រះចៅអធិរាជចិនក៏ត្រាស់បញ្ជាឱ្យព្រះសង្ឃមួយព្រះអង្គនិមន្តមកកាន់ ឬក៏ជាការផ្តល់ប្រយោជន៍ទៅវិញទៅមកតែប៉ុណ្ណោះ។



ព្រះពុទ្ធអង្គមហាយាន រាជវង្សស្វយ (ឆ្នាំ៥១៨-៦១៨)
(ប្រភព ៖ បណ្ឌិត មីសែល ត្រាណេ)

ក្រៅពីព័ត៌មានពាក់ព័ន្ធទៅនឹងតង្វាយនៃព្រះរូបឯកសារចិនក៏បានផ្តោតទៅលើសកម្មភាពផ្សព្វផ្សាយនៃលទ្ធិព្រះពុទ្ធសាសនា ប្រកបដោយចីរភាពតាមរយៈការចម្លងអត្ថបទគម្ពីរផ្សេងៗ។ របាយការណ៍ចិនបានបញ្ជាក់ឱ្យដឹងថាឆ្នាំ៥៣៥ និងឆ្នាំ៥៤៥ ព្រះមហាក្សត្រចិនបានបញ្ជូនរាជទូតរបស់ព្រះអង្គទៅកាន់ទឹកដីហ្វូណាន ដើម្បីចម្លងគម្ពីរព្រះពុទ្ធសាសនា។ ព្រះចៅអធិរាជខ្មែរនាជំនាន់នោះ បានបញ្ជូនព្រះភិក្ខុឥណ្ឌាមួយព្រះអង្គ ដែលប្រកបដោយចំណេះដឹងយ៉ាងខ្ពង់ខ្ពស់គឺព្រះភិក្ខុ **បរមត្ថា** មកពីទីក្រុង **អុជយ-យិនី** ទៅកាន់ប្រទេសចិន។ ក្នុងព្រះរាជបេសកកម្មនេះ ព្រះសង្ឃឥណ្ឌាបាននាំអត្ថបទចំនួន២៤០បាច់ទៅជាមួយព្រះអង្គផងដែរ។

ប្រសិនបើយើងពិនិត្យពុទ្ធបដិមាកម្មខ្មែរនៅក្នុងទឹកដីហ្វូណន ក្នុងអំឡុងពេលនៃទំនាក់ទំនងខាងវប្បធម៌ដែលតាមពិតទៅគឺជាការពង្រឹងសកម្មភាពសេដ្ឋកិច្ចផងដែរនោះ យើងនឹងឃើញថាពុទ្ធបដិមាខ្មែរមួយចំនួនពិតជាបានទទួលឥទ្ធិពលចិនយ៉ាងពិតប្រាកដមែន។ ករណីនេះក៏ដូចទៅនឹងតឹកតាងដ៏មានទម្ងន់មួយទៀត គឺវត្តមាននៃព្រះពុទ្ធបដិមាចិនដែលបង្ហាញថាមានជនជាតិចិនរស់នៅក្នុងអាណាចក្រហ្វូណន។ ទំនាក់ទំនងនេះត្រូវបានបន្តរហូតមកដល់សម័យក្រោយៗ ដោយឡែកសម័យអង្គរដែលខ្មែរបាននាំចូលកុលាលភាជន៍និងក្រណាត់សូត្រយ៉ាងសន្ធឹកសន្ធាប់ពីចិន។

ពុទ្ធសាសនិកខ្មែរតែងតែមានបំណងប្រាថ្នាចង់ដឹង ចង់ស្គាល់ប្រភពអត្ថន័យស៊ីជម្រៅរបស់លទ្ធិព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ដូច្នេះហើយបានជាកន្លងមកក៏មានការស្រាវជ្រាវយ៉ាងជ្រៅជ្រះអំពីព្រះធម៌ពុទ្ធវចនៈរបស់ព្រះសម្មាសម្ពុទ្ធពីអ្នកប្រាជ្ញខ្មែរ និងបរទេសធំៗ។ ដើម្បីពង្រីកការយល់ដឹងផ្នែកពុទ្ធសាសនាខ្មែរឱ្យកាន់តែស៊ីជម្រៅថែមមួយកម្រិតទៀត យើងសូមលើកយកចម្លាក់ព្រះពោធិសត្វមួយព្រះអង្គឆ្លាក់លើត្បូងកែវសមួយមកផ្សព្វផ្សាយ។ ព្រះពុទ្ធរូបនេះបានមកពីភូមិកំពង់ពោធិ៍ ស្រុកអង្គរបុរី ខេត្តតាកែវ។ ហើយមូលហេតុចម្បងនៃអត្ថបទនេះ គឺកូនត្បូងបន្ដោងខ្សែកនេះមានខ្លឹមសារដ៏វិសេសវិសាល ដោយហេតុថាវាបង្ហាញសន្ទុះជំនឿដ៏មុតមាំរបស់ពុទ្ធសាសនិកក្នុងអំឡុងសតវត្សទី៣-៤នៃគ្រិស្តសករាជ ក្នុងដែនដីនៃរាជធានីខ្មែរមួយចំនួនរបស់ហ្វូណន។

ក្រៅពីនេះ ជម្រៅមួយទៀតនៃការបដិបត្តិព្រះធម៌នាសម័យនោះ ដែលគួសបញ្ជាក់តាមរយៈចម្លាក់បុរាណក៏បង្ហាញមិនត្រឹមតែភាពរីកចម្រើនលូតលាស់ខាងព្រះពុទ្ធសាសនានិកាយមហាយានតែប៉ុណ្ណោះទេ ក៏ប៉ុន្តែអត្ថិភាពនៃទំនាក់ទំនងខាងវប្បធម៌រវាងខ្មែរនិងចិនផងដែរ ដូចជាសិល្បៈចិនបានជះឥទ្ធិពលដ៏ត្រចះត្រចង់លើពុទ្ធបដិមាកម្មខ្មែរនាគ្រាបឋមនៃប្រវត្តិ-សាស្ត្រកម្ពុជាជាដើម។ ទំព័រប្រវត្តិសាស្ត្របានចែងថាក្នុងរវាងសតវត្សទី៣-៤នៃគ្រិស្តសករាជទំនាក់ទំនងរវាងខ្មែរនិងឥណ្ឌា ទំនាក់ទំនងរវាងខ្មែរនិងចិន ក៏មានការលូតលាស់យ៉ាងខ្លាំងក្លាបំផុត ជាពិសេសក្រោយទស្សនកិច្ចជាផ្លូវការទូតរបស់លោក **ជូយីង** និង **កាំងថៃ** នៅឆ្នាំ២៣០។ អាស្រ័យដោយការជ្រួតជ្រាបនូវអត្ថន័យនិងអត្ថរសដ៏ជ្រាលជ្រៅរបស់ព្រះធម៌ជាពុទ្ធវចនៈរបស់ព្រះបរមគ្រូនៃយើង ព្រះចៅក្រុងចិនក៏បាននិមន្តព្រះភិក្ខុសង្ឃខ្មែរពីរអង្គនៅហ្វូណនទៅប្រែព្រះគម្ពីរព្រះពុទ្ធសាសនានៅប្រទេសចិន។ បើយើងពិនិត្យពីចម្លាក់ព្រះពោធិសត្វរបស់ខ្មែរ និងចិនក្នុងសម័យកាលនោះ យើងពិតជាអាចសម្គាល់ឃើញថាព្រះពោធិសត្វរបស់ខ្មែរបានយកលំនាំ

តាមចិន។ ចម្លាក់ព្រះពុទ្ធអង្គសក្យៈមុនីគោត្តមដែលក្នុងកែវភ្នែកឬក្នុងដួងព្រលឹងរបស់ខ្មែរជំនាន់ដើមក៏រមែងតែងនាំមកនូវសេចក្តីកក់ក្តៅ សេចក្តីសង្ឃឹម សុខសន្តិភាព ភាពសម្បូរសប្បាយ ពោលគឺឥតមានទុក្ខសោក រោគភ័យឧបទ្រពចង្រៃណាទាំងអស់មកបៀតបៀនយាយី កាលបើមានព្រះរូបនោះជាប់នឹងខ្លួន។



កំណាត់ត្រាលោក កាំងថៃ

(ប្រភព ៖ បណ្ឌិត មីសែល ត្រាណេ)

មកដល់សព្វថ្ងៃនេះ ស្ថានភាពខាងលើក៏មិនទាន់ផ្លាស់ប្តូរប្រែប្រួលប៉ុន្មានដែរ ពីព្រោះខេមរជនគ្រប់រូបដែលប្រាកចាកព្រះធម៌រមែងតែវិនាសមហន្តរាយសាបសូន្យ។ ជនជាតិខ្មែរយល់ថាសុភមង្គលសិរីសួស្តីនឹងមិនអាចកើតឡើងបាននៅទីណាមួយជាដាច់ខាតកាលបើព្រះធម៌មិនបានសណ្ឋិតឬប្រតិស្ថាននៅទីនោះ។ ខ្មែរជំនាន់នោះយល់ឃើញថាព្រះពោធិសត្វបែបចិនមានគុណបំណាច់ដ៏លើសលប់លើពួកគេពោលគឺអាចសង្គ្រោះគេមិនឱ្យវិនាសដោយផ្តល់តែសេចក្តីសុខភាពត្រជាក់ត្រជុំដ៏ស័ក្តិសិទ្ធ។ នៅមានហេតុផលមួយទៀតគឺថាព្រះរូបតំណាងព្រះពោធិសត្វមកពីក្រៅ ឬក៏ធ្វើតាមបែបចិន ត្រូវប្រជាជនខ្មែរបុរាណចាត់ទុកថាជាវត្ថុស័ក្តិសិទ្ធជាទីបំផុតផងដែរ។ ហេតុនេះឆ្លងកាត់ការវិភាគ យើងអាចសន្និដ្ឋានបានថាភាពរុងរឿងនៃលទ្ធិមហាយានជាពិសេសទំនាក់ទំនងរវាងសិល្បៈចិននិងខ្មែរ ដែលសព្វថ្ងៃត្រូវបានកប់បាត់ក្នុងអតីតកាលត្រូវបានរស់ឡើងវិញតាមរយៈរូបសំណាកតំណាងព្រះពោធិសត្វអវលោកេតេស្វរៈ។ នេះហើយជាហេតុដើមដែលបាននាំយើងឱ្យសិក្សាអំពីរូបចម្លាក់បុរាណបែបមហាយានខាងលើនេះ។

## ២.១.៣-កង់រទេះគោ

ក្នុងការស្រាវជ្រាវដ៏ខ្លីនេះ យើងត្រូវកំណត់ព្រំដែននៃប្រធានបទរបស់យើង ពោលគឺយើងគ្រាន់តែពិនិត្យលើទម្រង់នៅកង់រទេះគោ ឬសេះនាសម័យវប្បធម៌អង្គរបុរីនារអាណាចក្រហ្វូណន ដែលជាផ្នែកមួយនៃរទេះគោទាំងមូល។

យើងបានដឹងហើយថាការបើកទំព័រប្រវត្តិសាស្ត្រនៃនគរហ្វូណន ដែលជាព្រះរាជាណាចក្រខ្មែរដំបូងបង្អស់នៅដើមសតវត្សទី១នៃគ្រិស្តសករាជ ត្រូវបានធ្វើឡើងដោយឥទ្ធិពលឥណ្ឌាក៏មែនពិត ក៏ប៉ុន្តែទន្ទឹមនឹងនេះ ជនជាតិខ្មែរនាសម័យនោះក៏បានខ្ចីសារជាតុឬសមាសធាតុវប្បធម៌ចិនដ៏ក្រាស់ក្រែលដែរ ដើម្បីអភិវឌ្ឍសង្គមជាតិរបស់ខ្លួនដែលកំពុងស្ថិតក្នុងចរន្តនៃ



ចម្លាក់រទេះគោខ្មែរនៅប្រាសាទបាយ័ន (ប្រភព ៖ www.featurepics.com)

សាកលូបនីយកម្ម។ ម្លោះហើយជាការធម្មតាទេ សំណង់គ្រឹះនៃវប្បធម៌ខ្មែររមែងតែពាក់ព័ន្ធជាមួយវប្បធម៌ចិន។

ក្នុងការពិនិត្យមើលលក្ខណៈរបស់រទេះគោខ្មែរក្នុងសង្គមខ្មែរបុរាណ បើប្រៀបធៀបទៅនឹងកង់រទេះសេះរបស់ចិនដែលអាយុកាលជាង២.៣០០ឆ្នាំហើយ ដែលគេបានរកឃើញក្នុងសម័យ Qin Shi Huangdi ។



រទេះគោខ្មែរបច្ចុប្បន្ន

ការវិភាគបានឱ្យឃើញឧបមាណវិធីដែលជាកត្តាបញ្ជាក់អំពីទីទំនាក់ទំនងរវាងបច្ចេកវិធីធ្វើកង់រទេះខ្មែរនិងចិនដែលយើងជឿថាមានកម្ចីពីចិន។ ក្នុងន័យនេះ បើយើងពិនិត្យពីភិនភាគនៃកង់រទេះគោខ្មែរនិងរទេះសេះចិន យើងឃើញមានអន្តរកម្មវប្បធម៌ និងបច្ចេកទេសដោយឥតប្រកែកបាន។

ចំពោះយើង ទំនាក់ទំនងខាងវប្បធម៌នេះអាចចាត់ទុកថាជាតថភាពរបស់ប្រវត្តិសាស្ត្រជាទូទៅ និងសង្គមខ្មែរដែលមានការវិវត្តប្រែប្រួលមិនឈប់ឈរតាមលក្ខខណ្ឌនៃឥទ្ធិពលវប្បធម៌មកពីក្រៅ។ ក៏ប៉ុន្តែទន្ទឹមនឹងនេះ យើងក៏មិនអាចកាត់រទេះគោឱ្យដាច់ចេញពីឥទ្ធិពលឥណ្ឌាដែរ។ ដោយហេតុថារទេះគោខ្មែរនាសម័យបុរេអង្គរនិងអង្គរ មានប្រភពចេញពីប្រទេសឥណ្ឌា ហើយឥទ្ធិពលចិនគ្រាន់តែជះឥទ្ធិពលលើកង់រទេះតែប៉ុណ្ណោះ។

ប្រការទាំងនេះហើយដែលធ្វើឱ្យយើងសន្និដ្ឋានបានថារទេះគោខ្មែរមិនមែនមកពីប្រទេសចិនទេ តែមកពីប្រទេសឥណ្ឌា ពោលគឺមិនដែលចោទជាបញ្ហានៅទីនេះដែលប្រភពនេះ តែជាភាពខុសគ្នារវាងការតុបតែងកង់ទៅវិញដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាប់នឹងចិន។ ខាងលើនេះបង្ហាញបញ្ជាក់អំពីបច្ចេកវិទ្យាខ្មែរបុរាណដែលប្រកបដោយគំនិតកៃច្នៃនិងទេពកោសល្យកម្រិតខ្ពស់។

តាមការពិត ថ្វីត្បិតតែរទេះគោខ្មែរមានប្រភពពីឥណ្ឌាដែលត្រូវបានបញ្ជាក់តាមរយៈចម្លាក់ យើងយល់ឃើញថាកង់របស់វាពិតជាកម្មវីពីចិនយ៉ាងពិតប្រាកដ។ ហើយកម្មវីនេះគឺជាការបំពេញបន្ថែមលើធាតុខ្វះខាតហើយជាទំនើបកម្មដែលធ្វើឱ្យការដឹកជញ្ជូនកាន់តែងាយស្រួល។ កុំភ្លេចថារហូតដល់សព្វថ្ងៃ រទេះគោខ្មែរដែលត្រូវបាននិម្មិតឡើងដោយទំនាក់ទំនងវប្បធម៌ឥណ្ឌា និងចិននៅតែរក្សាតួនាទីយ៉ាងសំខាន់របស់ខ្លួនក្នុងសង្គមបច្ចុប្បន្ននៅឡើយ[៩]។

## ២.១.៤-កុលាលភាជន៍

ដោយហ្វូណនស្ថិតក្នុងចរន្តសាកលូបនីយកម្ម ជនជាតិខ្មែរនៅក្នុងភូមិភាគខាងត្បូងនៃប្រទេសថៃបច្ចុប្បន្ន និងនៅក្នុងភូមិភាគនៃដែនដីសណ្តនៃទន្លេមេគង្គបានទទួលទំនិញពីចិនយ៉ាងក្រាស់ក្រែល។ របស់របរដែលនាំចូលពីប្រទេសចិន មានសំពត់សូត្រ និងកុលាលភាជន៍ដែលមានចំនួនយ៉ាងច្រើនដែលជាទូទៅសព្វថ្ងៃនៅសល់តែបំណែកបាក់បែក។

វត្តមានរបស់របរប្រើប្រាស់ឬក៏គ្រឿងអលង្ការចិនទាំងឡាយដែលជនជាតិខ្មែរស្វះស្វែងរកឆ្លុះបញ្ចាំងឱ្យយើងឃើញកម្រិតស៊ីវីល័យដ៏ខ្ពស់របស់អ្នកស្រុកហ្វូណន។ ទំនិញល្អៗរបស់អភិជនទាំងចិន ទាំងឥណ្ឌារមែងតែងអូសទាញសន្តានចិត្តរបស់ជនជាតិខ្មែរ។



កុលាលភាជន៍នាសម័យហ្វូណន (ប្រភព ៖ www.cen.com.kh)

(៩) www.cen.com.kh/Culture

ដូចពោលខាងលើ កុលាលភាជន៍ទាំងនោះត្រូវបានបែកបាក់អស់ហើយ នៅសល់តែបំណែក តែបានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងទំនាក់ទំនងខ្មែរ - ចិននាសតវត្សទី៧នៃគ្រិស្តសករាជផងដែរ។

ដោយសារតែស្លាកស្នាមខាងបុរាណវិទ្យាចិនទាំងនោះហើយ ទើបយើងបានឃើញពន្លឺចែងចាំងរបស់កម្រិតវប្បធម៌បុរាណ។ មួយវិញទៀត យើងក៏សង្កេតឃើញថាបន្ទាប់ពី **សន្តតិវង្សថាំង** ជនជាតិចិននៅតែបន្តទំនាក់ទំនងវប្បធម៌និងសេដ្ឋកិច្ចខ្មែររហូតដល់បច្ចុប្បន្នភាព។

សម្ព័ន្ធភាពនយោបាយរវាងខ្មែរនិងចិន ក៏ត្រូវពង្រឹងតាមរយៈវិស័យសេដ្ឋកិច្ចដែរ ដូចវត្ថុមានរបស់សំពៅចិនដែលធ្លាក់លើប្រាសាទបាយ័នជាសក្ខីភាពស្រាប់។ នៅក្នុងរាជធានី



កុលាលភាជន៍នៃសន្តតិវង្សថាំង (ប្រភព ៖ www.cen.com.kh)

**យសោធបុរៈ** ដែលជាទីក្រុងដ៏សំខាន់ជាងគេ ព្រោះមានព្រះមហាក្សត្រិយ៍ប្រថាប់នៅ គេតែងតែឃើញមានការនាំចូលកុលាលភាជន៍ចិននៅសម័យសុង។ វត្ថុមាននៃក្រឡ ថូ ចាន របស់ចិនជាភស្តុតាងបង្ហាញឱ្យឃើញចំណងទាក់ទងគ្នាលើវិស័យពាណិជ្ជកម្មជាមួយនឹងចិន។ វត្ថុទាំងនោះក៏ជាភស្តុតាងបញ្ជាក់ពីវត្តមានរបស់ស្ថានទូតចិននៅក្នុងចក្រភពអង្គរផងដែរ។ ដូចនេះ យើងបានដឹងរួចមកហើយការណ៍ដែលលោក **ជីវតាក្វាន់** បានអញ្ជើញមកទស្សនាទីក្រុងអង្គរធំជាសក្ខីកម្ម បង្ហាញពីការពង្រឹងវិស័យសេដ្ឋកិច្ចនិងនយោបាយរវាងប្រទេសទាំងពីរដែលធ្លាប់មានតាំងពីសម័យមុនៗមក និងបានបន្តរហូតមកដល់សម័យបច្ចុប្បន្នយើងនេះ។ ប្រទេសខ្មែរនាសម័យអង្គរក៏បានទទួលពីចិននូវសំពត់ដែលមានពណ៌ចម្រុះ ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការប្រើប្រាស់ក្នុងសង្គម ដូចជាវាំងននសម្រាប់តុបតែងខ្លោងទ្វារឬទ្វារ បង្អួច ផ្ទះ

សម្លៀងឬប្រាង្គប្រាសាទ។

ក្រៅពីការនាំចូលកុលាលភាជន៍ចិន គេសង្កេតឃើញមានកុលាលភាជន៍ខ្មែរដែលមានលក្ខណៈជាកូនកាត់។ លក្ខណៈកូនកាត់នៃក្រឡចានក្បានមួយចំនួន គ្រាន់តែបង្ហាញឱ្យឃើញនូវសន្ទុះនៃកម្រិតឥទ្ធិពលវប្បធម៌ចិនមកលើសង្គមខ្មែរប៉ុណ្ណោះ ប៉ុន្តែគ្មានអ្វីអាចឱ្យគេសន្និដ្ឋានបានថាជនជាតិចិនបានបង្រៀនខ្មែរឱ្យចេះសូនកុលាលភាជន៍ដែលជាប្រពៃណីរបស់ខ្មែរតាំងពីសម័យយុគវប្បធម៌ថ្មរំលីង ពោលគឺតាំងពីរវាង៣៥០០ឆ្នាំមុនគ្រិស្តសករាជម្ល៉េះ។

ការទាក់ទងគ្នាខាងវិស័យវប្បធម៌រវាងខ្មែរនិងចិនគ្រាន់តែបានជួយឱ្យបច្ចេកទេសបង់ពណ៌របស់ខ្មែរកាន់តែមានភាពល្អវិចិត្រឡើងប៉ុណ្ណោះ។ ហេតុនេះហើយ បានជាកុលាលភាជន៍ខ្មែរនាសម័យអង្គរមិនគ្រាន់តែមានភាពសម្បូរបែបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានពណ៌ផូរផង់រលើបរលោងយ៉ាងល្អប្រណីតគួរឱ្យចង់គយគន់ពន់ពេកទៀតផង។

## ២.១.៥-តន្ត្រី

### ក-តន្ត្រីខ្មែរ

លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លូត ធីតា** បានអះអាងថា ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនមានទំនាក់ទំនងជាមួយគ្នាយូរលង់ណាស់មកហើយ ព្រោះប្រទេសយើងទាំងពីរសុទ្ធសឹងជាប្រទេសដែលមានវ័យចំណាស់នៅអាស៊ីនេះ។ ឯកសារស្តីពីទំនាក់ទំនងរវាងប្រទេសយើងទាំងពីរមានយ៉ាងច្រើនទាំងភាសាខ្មែរ និងភាសាចិន ហើយបានផ្សព្វផ្សាយទាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិននេះ។ តាមសៀវភៅប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា និងចិនសុទ្ធតែបានឯកភាពថាកម្ពុជានៅក្នុងសម័យហ្វូណនមាន **តន្ត្រី** ដ៏ល្បី ហើយព្រះរាជាខ្មែរក៏បានចាត់វង់តន្ត្រីមកសម្តែងនៅប្រទេសចិនផងដែរ។ តន្ត្រីនេះបានទទួលនូវការកោតសរសើរពីព្រះរាជានៃនគររបស់ចិនទៀតផង។

### ខ-តន្ត្រីករ និង យឹមចិន

ប្រសិនបើគេលើកយកវិស័យពាណិជ្ជកម្មតែម្យ៉ាងមកនិយាយ គេឃើញថាប្រទេសចិនដែលជាមហាប្រទេសឬចក្រភពបានទទួលជោគជ័យក្នុងការធ្វើជំនួញក្នុងតំបន់អាស៊ីអាគ្នេយ៍ជាពិសេសជាមួយអតីតព្រះរាជាណាចក្រកម្ពុជាដ៏រុងរឿងថ្កើងថ្កាន។ ភាពជោគជ័យនេះពិតជាមានលក្ខណៈជាទូទៅដោយហេតុថាជានិច្ចកាលឥទ្ធិពលចិនមកលើខ្មែរមានទាំងប្រយោលទាំង

ក្នុងសកម្មភាពជាក់ស្តែង។ គ្រប់សម័យកាល ចិនតែងតែបានបញ្ជូនរាជទូតរបស់ខ្លួនមកកាន់ព្រះរាជាណាចក្រកម្ពុជា ក្នុងបរិបទនេះយើងឃើញថាចិនមានការចងសម្ព័ន្ធមិត្តយ៉ាងជិតស្និទ្ធជាមួយខ្មែរ។

តាមរូបចម្លាក់ គួរគប្បីជ្រាបថា ពេលខ្លះមានការដោះដូរតង្វាយមានក្រុមតន្ត្រីករចិនច្រៀង រាំ ប្រសិនបើពិនិត្យលើកាយវិការរបស់ពួកគេឬក៏វត្ថុខ្លះដែលពួកគេកាន់នៅដៃ រូបចម្លាក់នេះអាចនឹងត្រូវបានឆ្លាក់ក្នុងសម័យកាលដែលលោកអគ្គរាជទូតរបស់អធិបរាជ **គុប៊ីឡាយខាន់** នៃសន្តិវង្សម៉ុងហ្គោលកាន់កាប់ប្រទេសចិន បានអញ្ជើញមកធ្វើទស្សនកិច្ចនៅទីក្រុងអង្គរធំក្នុង



ចម្លាក់តន្ត្រីករចិននៅអង្គរធំ ( ប្រភព ៖ www.cen.com.kh )

ឆ្នាំ១២៩៧។

រូបចម្លាក់តំណាងជនជាតិចិនដែលគេបានជួបប្រទះក្នុងសម័យអង្គរ គឺជាភស្តុតាងមួយយ៉ាងសំខាន់បង្ហាញតួនាទីរបស់ជនជាតិចិននៅក្នុងរាជធានីអង្គរធំ។ វាជាទិន្នន័យមួយគួរឱ្យចាប់អារម្មណ៍ ដើម្បីបង្ហាញពីទំនាក់ទំនងឥតដាច់រវាងប្រទេសយើងទាំងពីរ។

ក្រៅពីតន្ត្រីករចិន យើងឃើញថាប្រភពនៃឧបករណ៍ភ្លេងខ្មែរ គឺ **ឈិង** ពិតជាបានទទួលពីចិន។ ការនិយមនូវឧបករណ៍ **ឈិង** ត្រូវបានចារនៅលើផ្ទាំងសិលាចារឹក K669 និង

K270 នៅសតវត្សទី១០។ យ៉ាងណាមិញ ខ្មែរបុរាណក៏បានឆ្លាក់ឧបករណ៍ **ឈិង**[១០] នេះនៅលើហោជាងនៃប្រាសាទបន្ទាយស្រីដែលបានសាងសង់នៅឆ្នាំ៩៩៦ ជញ្ជាំងប្រាសាទអង្គរវត្ត និងប្រាសាទបាយ័នដែលបានសាងសង់ដោយ **ព្រះបាទសុរិយាវរ្ម័នទី២** និង **ព្រះបាទជ័យវរ្ម័នទី៧**។ ក៏ប៉ុន្តែយើងក៏បានរកឃើញឧបករណ៍ **ឈិង** នៅក្នុងស្ថានីយបុរេអង្គរមួយចំនួនដូចជានៅអូរកែវ និងអង្គរបុរីដែលអាចបញ្ជាក់ថាបុរាណភាពនៃគ្រឿងភ្លេងនេះមានតាំង



ឃឹមខ្មែរ

ពីដើមសតវត្សទី១ នៃគ្រិស្តសករាជមកម្លេះ។

**ឃឹម** គឺជាឧបករណ៍ភ្លេងដែលមានប្រភពចេញពីចិន ដែលគេច្រើនតែប្រើក្នុងល្ខោនហ៊ីចិន និងក្នុងល្ខោនបាសាក់ខ្មែរ នៅឯដែនដីសណ្តកម្ពុជាក្រោម ដែលបានទទួលឥទ្ធិពលពីចិនមុនមកដល់ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន។ ឥឡូវនេះ **ឃឹម** ត្រូវបានបញ្ចូលក្នុងវង់តន្ត្រីអាយ៉ៃមហោរី និងអាពាហ៍ពិពាហ៍ថែមទៀតផង។

ទម្រង់នៃ **ឃឹម** មានរាងដូចជាសត្វមេអំបៅត្រដាងស្លាប។ រីឯតួឬស្នូករបស់វាគឺធ្វើអំពីឈើខ្លឹមក៏ដូចជាឈើផ្ចឹកនិងដូងថែមជាដើម។ វាមានលក្ខណៈស្តើង ស្រាល ដើម្បីងាយនឹងដឹកជញ្ជូនក្នុងពេលធ្វើដំណើរជិតឆ្ងាយ។

ឧបករណ៍ **ឃឹម** ចែកចេញជាពីរសណ្ឋានគឺ **សន្ទះលើ** និង **សន្ទះក្រោម**។ ម្យ៉ាងទៀតនៅប្រទេសកម្ពុជាយើង **ឃឹម** មានពីរប្រភេទគឺ **ឃឹមធំ** និង **ឃឹមតូច**។ លក្ខណៈវិសេសវិសាលរបស់ឧករណ៍នេះ គឺប្រើសំនៀងផ្គក់កាក់ពីមុខពីក្រោយ ដូចរនាតធុង ជាហេតុធ្វើឱ្យវាលេចធ្លោ

---

(១០) ជាឧបករណ៍តន្ត្រីមានទំហំតូចស្ថិតក្នុងក្រុមនៃគ្រឿងគោះ។ វាមានរាងដូចដោះក្រមុំ ដោយមានចោះរន្ធមួយនៅចំកណ្តាលកំពូលសម្រាប់តភ្ជាប់ពីមួយទៅមួយទៀត ខ្មែរយើងប្រើវាជាគូ ដោយកាន់នៅដៃហើយគោះផ្ទប់គ្នាតាមចង្វាក់ភ្លេងគួរឱ្យចាប់អារម្មណ៍ជាអនេក។

ខ្ពស់ជាងឧបករណ៍តន្ត្រីផ្សេងៗឯទៀតនៅពេលដែលគេប្រគំ។

ឧបករណ៍ **ឃឹម** មានខ្នង់ពីរជួរ ខ្នង់មួយជួរៗមានខ្នង់៧ខ្សែ នៅខ្នង់លើជួរខាងឆ្វេងមានសូរសំនៀងលេងទាំងសងខាង រីឯខ្សែនៅលើខ្នង់ជួរខាងស្តាំមានសូរសៀងលេងបានតែម្ខាងទេ។ ម្ខាងទៀតខ្នង់ទាំងសងខាងឆ្វេងនីមួយៗមានខ្សែសំនៀង៣សរសៃដែលធ្វើអំពីស្ពាន់ដែលគេដាក់ផ្ទួបគ្នា។ រីឯ ខ្នង់ក្រោមវិញមានសំឡេងសរសៃទេ។ ក្រៅពីនេះ យើងឃើញមានរបួតសម្រាប់ចងខ្សែនិងរឹតសូរធ្វើអំពីដែកមានម្ខាង ៤០។ សូមបញ្ជាក់ដែរថាគេលេងឧបករណ៍ **ឃឹម** ដោយវាយនឹងអន្លូងធ្វើអំពីឫស្សី។

ផ្អែកលើទម្រង់ **ឃឹមខ្មែរ** និង **ឃឹមចិន** ដែលជាលក្ខណៈសម្គាល់ជាក់ស្តែង យើងអាចនិយាយយ៉ាងត្រឹមត្រូវថា ឧបករណ៍ឃឹមនេះមានប្រភពចេញពីឧបករណ៍ចិនប្រាកដ។ ការសន្និដ្ឋាននេះមិនមែនជាសម្មតិកម្ម ប៉ុន្តែជាកម្ទីវប្បធម៌យ៉ាងពិតប្រាកដ[១១]។



ឃឹមចិន

## ២.១.៦-ល្បែងឆ្អិនឆ្អែត

ក្នុងគោលបំណងបង្កើនបរិយាកាសឱ្យមានភាពសប្បាយរីករាយនៅក្នុងបុណ្យទានធំៗ គេបានបង្កើតល្បែងមួយចំនួន ដូចជា ឈុតឈរតម្រៀបជាន់លើគ្នា ឈុតជិះដំរីវាយកូនឃ្លីការបង្វិលខ្លួនលើចុងបង្គោលឈើ ឈុតដើរសួរលើព្រ័ត្រ ឈុតលេបកាំបិតវែងនិងខ្លី និងឈុតដើរលើកទម្ងន់ជាដើម ត្រូវបានវិចិត្រករខ្មែរឆ្លាក់លើប្រាសាទបាយ័នទុកជាតឹកតាង។

អ្វីដែលជាការកត់សម្គាល់នោះ គឺប្រសិនបើយើងទស្សនាឈុតសៀកចិនខ្លះ យើងមានអារម្មណ៍ថាមានលក្ខណៈដូចគ្នានឹងចម្លាក់ខ្មែរដែលបានឆ្លាក់នៅប្រាសាទបាយ័ន។ ភាពស្រដៀងគ្នារវាងប្រភេទល្បែងខ្មែរនិងល្បែងរហស្សកម្មចិន ជាទិន្នន័យដ៏សំខាន់ដែលអាចធ្វើឱ្យ

(១១) www.cen.com.kh/Culture

យើងហ៊ានសន្និដ្ឋានថាល្បែងខ្មែរពិតជាមានទំនាក់ទំនងខាងសិល្បៈទស្សនីយភាពជាមួយចិន។ តែទោះបីជាប្រភពពិតនៃល្បែងទាំងនោះ ត្រូវបានមកពីប្រទេសចិនក៏ពិតមែន តែកាយវិការសម្លៀកបំពាក់ និងបរិបទវប្បធម៌សង្គមមិនដូចនឹងរបស់ចិនទេ រួមទាំងឧបករណ៍តន្ត្រីប្រគំក្នុងពេលសម្តែងផងដែរ។ នេះជាភាពប៉ិនប្រសប់នៃកម្រិតខេមរយានកម្ម[១២]។



ចម្លាក់សៀកនៅប្រាសាទបាយ័ន (ប្រភព ៖ www.cen.com.kh)

## ២.១.៧-ប្រភពចក្រសត្វទាំង១២របស់ខ្មែរ

ចក្រសត្វទាំង១២ ដែលជនជាតិខ្មែរប្រើជារបៀបរាប់ឆ្នាំនោះ ចេញប្រភពមកពីចិន ពិសេសនៅសម័យបុរេអង្គរ និងអង្គរ គឺពុំមែនខ្ចីពាក្យទាំងនោះមកពីឥណ្ឌានោះទេ។ ការណ៍នេះគ្មានអ្វីភ្ញាក់ផ្អើលឡើយ ប្រពៃណីនេះមានប្រភពពីចិន ព្រោះទំនាក់ទំនងខ្មែរ-ចិនមានភាពស្និតរលូនរាប់សតវត្សមកហើយ។

ការនិយមរបៀបរាប់ឆ្នាំមានចក្រសត្វទាំង១២ មានតួនាទីយ៉ាងសំខាន់ក្នុងសង្គមខ្មែរបច្ចុប្បន្ន ប្រសិនបើជាគេសំអាងលើទំនាយទូទៅសម្រាប់មនុស្សកើតក្នុងឆ្នាំទាំង១២នោះ។ ភាពស្រដៀងគ្នាក្នុងការប្រើសត្វទាំង១២រវាងខ្មែរនិងចិន បើទោះជាឈ្មោះសត្វជាភាសាខ្មែរក៏ដោយចុះ។ ការរាប់ឈ្មោះសត្វទាំងនោះតំណាងឱ្យឆ្នាំនីមួយៗមានដូចជាឆ្នាំជូត(កណ្ដុរ) ឆ្លូវ(គោ) ខាល(ខ្លា) ថោះ(ទន្សាយ) រោង(នាគ) ម្សាញ់(ពស់) មមី(សេះ) មមែ(ពពែ) វក(ស្វា) រកា(មាន់) ច(ឆ្កែ) និងឆ្នាំកុរ(ជ្រូក)។

តាមសិលាចារឹករបស់ព្រះបាទ **សុរិយាវរ្ម័នទី១** ដែលបានចារឡើងនៅឆ្នាំ៩២១ ជា

(១២) www.cen.com.kh/Culture

ភស្តុតាងមួយយ៉ាងសំខាន់ស្តីពីការនិយមប្រើចក្រ១២ឆ្នាំ ដោយមានសត្វជាតំណាង។ នៅសម័យអង្គរ និងក្រោយអង្គរ ការនិយមរាប់ដូចខាងលើក៏នៅតែមានជាហូរហែ។ ភស្តុតាងខាងបុរាណវិទ្យាទាំងនេះបានបញ្ជាក់ថា ខ្មែរមានការនិយាយរាប់ចក្រដែលមានរយៈពេល១២ឆ្នាំ ដោយមានសត្វនីមួយៗជាតំណាងឆ្នាំនីមួយៗ ខ្មែរពុំបានខ្ចីចក្រនេះពីប្រទេសឥណ្ឌា ឬប្រទេសជិតខាង ថៃ ឡាវ ដែលជាប្រទេសចំណូលថ្មីនាសតវត្សទី១៣នោះឡើយ។ ក៏ប៉ុន្តែ ខ្មែរបានខ្ចីតាមរយៈពួកចិនទៅវិញទេ។

តាមលោក **ហ្សក់សឺដេស** (អ្នកប្រាជ្ញបារាំង) និយាយថាទំនាក់ទំនងរវាងខ្មែរ និងជនជាតិមឿង ឬពួង ដែលរស់នៅសព្វថ្ងៃក្នុងខេត្តថាញ់ហ្វាខាងជើងនៃប្រទេសយៀកណាមបានកើតមានតាំងតែសម័យបុរេអង្គរមកម្ល៉េះ តាមរយៈទីក្រុងស្រេស្ឋបុរៈ ក្បែរខេត្តកាមមន ម៉ុំចម្ប៉ាសាក់ តាមដងទន្លេមេគង្គ។ តំបន់នេះសព្វថ្ងៃប្រើពុទ្ធសករាជ ឬចុល្លសករាជ[១៣]។ សករាជទាំងពីរនេះ ចាស់បុរាណផ្តើមរាប់ឆ្នាំទី១ ជាស័កទី១ បើទោះបីជាពុទ្ធសករាជចាប់ផ្តើមរាប់ពីឆ្នាំម្សាញ់ និងចុល្លសករាជចាប់ផ្តើមពីឆ្នាំកុរក៏ដោយ។

សេចក្តីសន្និដ្ឋានខាងលើ យើងអាចដឹងតាមរយៈតារាងវាក្យស័ព្ទដូចខាងក្រោម[១៤] ៖

| តារាងវាក្យស័ព្ទ | | |
|---|---|---|
| ភាសាមនខ្មែរ ឬសំស្ក្រឹត | ភាសាខ្មែរប្រកពមឿង (កុលសម្ព័ន្ធយួន) | ភាសាយួន |
| កណ្តុរ | ជូត | ជូក |
| ថ្មុល ថ្មុំ (ភាសាសំស្ក្រឹត) | ឆ្លូវ | ត្រូវ (ចូវ) |
| ខ្លា | ខាល | កប |
| ទន្សាយ | ថោះ | ថ |
| នាគ (សំស្ក្រឹត) | រោង | រ៉ុង |
| ពស់ | ម្សាញ់ | រ៉ាំង |
| សេះ | មមី | ង៉ឿ |
| ពពែ | មមែ | យេ |
| ស្វា | វក | យី |
| មាន់ | រកា | ហ្គា |
| ឆ្កែ | ច | ច |
| ជ្រូក | កោរ កុរ | ហៃវ |

(១៣) ការតាំងចុល្លសករាជបានចាប់ផ្តើមនៅឆ្នាំ១១៨១ រីឯមហាសករាជតាំងឡើងនៅក្នុងកាលពុទ្ធសករាជ នៅខេត្តឆៃយ៉ា អតីតដែនដីនៃចក្រភពបុរេអង្គរនិងអង្គរ។

(១៤) www.cen.com.kh/Culture

ឆ្លងតាមការប្រៀបធៀបតារាងវាក្យស័ព្ទខ្មែរ ដែលមានប្រភពចេញពីភាសាមឿងដែលស្ថិតក្នុងអម្បូរចិន យើងអាចដឹងប្រភពទាក់ទិននឹងឈ្មោះសត្វខ្មែរមួយចំនួន។ នេះជាមូលដ្ឋានគ្រឹះនៃប្រពៃណីរាប់សត្វទាំង១២នៅកម្ពុជា ដែលជាប្រវត្តិសាស្ត្របានចារឹកទុក។

នៅសតវត្សទី១៣-១៤ ជនជាតិសៀម-លាវ ក៏បានខ្ចីរបៀបរាប់ឆ្នាំបែបនេះដោយមានចក្រសត្វទាំង១២តាមរយៈជនជាតិខ្មែរដែលជាអ្នកស្រុកដើមនៅក្នុងភូមិភាគនោះ។ ប្រការនេះយើងអាចជួបប្រទះលើផ្ទាំងសិលាចារិកថៃមួយចំនួន នៅរាជធានីសៀមដំបូង គឺ **សុខោទ័យ**។

ការសិក្សាសិលាចារឹកបានរកឃើញថាការប្រើចក្រសត្វទាំង១២ ស្ថិតក្នុងបរិបទដ៏ធំទូលាយមួយ គឺក្នុងចក្រភពកម្ពុជទេសតែម្តង ព្រោះយើងបានឃើញនៅប្រទេសថៃបច្ចុប្បន្ន ដូចជាសិលាចារឹកខ្មែរ K988 នៅអយុធ្យាចារនៅឆ្នាំ១៣៨០ សិលាចារឹក K943នៅភិមាយចារនៅឆ្នាំ១០៤១ និងសិលាចារឹក K413 ចារនៅឆ្នាំ១៣៤១។ យ៉ាងណាមិញ នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ន គេក៏បានជួបនូវសិលាចារឹកមួយចំនួនផងដែរដូចជា K357នៅខេត្តកំពង់ចាមចារនៅឆ្នាំ៩៩២ K618 នៅសៀមរាបចារនៅឆ្នាំ១០២៦ និងនៅតាកែវ K830ចារនៅឆ្នាំ១១០៦។ ទោះបីជាគេបានដឹងច្បាស់លាស់ អំពីកម្ចីសត្វទាំងនោះពីភាសាមឿងជារឿងត្រឹមត្រូវមែន ក៏ប៉ុន្តែយើងគិតថាពាក្យខ្លះពិតជាមានប្រភពពីចិនយ៉ាងប្រាកដដូចជាពាក្យ **រោង** ជាឧទាហរណ៍។

ជនជាតិខ្មែរក៏មានចក្រមួយទៀតសម្រាប់សម្គាល់ឆ្នាំ គឺចក្រដែលមានរយៈពេល៦០ឆ្នាំដោយចែកជា៦ក្រុម។ មួយក្រុមមាន១០ឆ្នាំ ដែលគេឱ្យឈ្មោះជាពិសេសថា **«ស័ក»** ដោយរាប់ពី១ដល់១០តាមលេខរៀង។ ការកត់ត្រា **«ស័ក»** នីមួយៗមានសារៈសំខាន់ណាស់ ព្រោះធ្វើឱ្យគេសម្គាល់បានថាឆ្នាំ ដែលមានហេតុការណ៍បានកន្លងផុតទៅនោះជាឆ្នាំណាមួយក្នុងចក្រ៦០ឆ្នាំ។ សម្រាប់ពុទ្ធសករាជខ្មែរចាប់ផ្តើមរាប់ពីឆ្នាំម្សាញ់ គឺជាសក័ទី១ ក៏ប៉ុន្តែដើម្បីគិតស័កគេឱ្យយកពុទ្ធសករាជដក១ ហើយចែកនឹង១០ ហើយលេខដែលសល់គឺជាស័ករបស់ឆ្នាំ។

- បើចែកទៅសល់ ០ គេថាឆ្នាំនោះជាឆ្នាំសំរិទ្ធស័ក។
- បើចែកទៅសល់ ១ គេថាឆ្នាំនោះជាឆ្នាំឯកស័ក។
- បើចែកទៅសល់ ២ គេថាឆ្នាំនោះជាឆ្នាំទោស័ក។
- បើចែកទៅសល់ ៣ គេថាឆ្នាំនោះជាឆ្នាំត្រីស័ក។
- បើចែកទៅសល់ ៤ គេថាឆ្នាំនោះជាឆ្នាំចត្វាស័ក។
- បើចែកទៅសល់ ៥ គេថាឆ្នាំនោះជាឆ្នាំបញ្ចស័ក។

- បើចែកទៅសល់ ៦ គេថាឆ្នាំនោះជាឆ្នាំឆស័ក។
- បើចែកទៅសល់ ៧ គេថាឆ្នាំនោះជាឆ្នាំសប្តស័ក។
- បើចែកទៅសល់ ៨ គេថាឆ្នាំនោះជាឆ្នាំអដ្ឋស័ក។
- បើចែកទៅសល់ ៩ គេថាឆ្នាំនោះជាឆ្នាំនព្វស័ក។

### ២.១.៨-កាំជ្រួច និង ផាវ

នៅប្រទេសកម្ពុជានាសម័យមហានគរ ខ្មែរមិនទាន់ចេះប្រើរំសេវឬគ្រឿងផ្ទុះនិងកាំភ្លើងធំធ្វើអំពីលោហៈដូចជាជនជាតិចិននៅឡើយទេ។ អាវុធទាំងនេះត្រូវបានប្រើប្រាស់ក្រោយអង្គរ នៅពេលខ្មែរមានទំនាក់ទំនងជាមួយពួកអឺរ៉ុបដែលប្រហែលជាបានខ្ចីអាវុធនោះពីចិនដោយបានកែច្នៃឱ្យមានប្រសិទ្ធភាពជាង។ ក្នុងដំណើរទស្សនកិច្ចនៅទីក្រុងអង្គរ លោក **ជីវតាក្វាន់** បានកត់ត្រានៅក្នុងកំណត់ត្រា ដោយបានបញ្ជាក់ថាក្នុងពិធីបុណ្យប្រពៃណីជាតិខ្មែរបានប្រើប្រាស់កាំជ្រួចនិងផាវ។ កាំជ្រួចខ្នាតតូចឬខ្នាតធំដែលខ្មែរបានប្រើប្រាស់នៅសម័យអង្គរទាំងនោះ គឺជាភស្តុតាងយ៉ាងជាក់ច្បាស់ពាក់ព័ន្ធនឹងអាជីវកម្មរវាងខ្មែរនិងចិន ទោះបីជាសិលាចារឹកចិនមិនបាននិយាយដល់ក៏ដោយ ព្រោះកាំជ្រួចនេះត្រូវបានរកឃើញដោយជនជាតិចិន[១៥]។

### ២.១.៩-សូត្ររបស់ចិន

លោក **ជីវតាក្វាន់** បានកត់ត្រាថា មន្ត្រីខ្មែរថ្នាក់ខ្ពស់ជិះគ្រែស្នែងប្រាក់និងក្លស់ដងមាសមួយ។ ក្លស់នោះគេយក **«សំពត់ជាតិសូត្រដែលធ្វើមកពីប្រទេសចិន»** ពាស ហើយទម្លាក់ចុងរំភាយចុងសឹងដល់ដី។ ឯឆ័ត្រតាំងយូ គេយកសំពត់សូត្រពណ៌ខៀវមកពាស ហើយទម្លាក់រំភាយខ្លីបន្តិចដែរ រួចយកប្រេងមកលាបយ៉ាងរលើបទៀតផង។ ក្លស់ដែលមន្ត្រីរាជការប្រើប្រាស់សម្រាប់បង្ហាញពីភាពថ្លៃថ្នូរ និងអំណាចរបស់ខ្លួនគឺជា **សូត្រក្រហម** ដែលផលិតនៅប្រទេសចិន។ មើលនៅត្រង់នេះអាចឆ្លុះបញ្ចាំងយ៉ាងជាក់ច្បាស់ថានៅចុងសតវត្សទី១៣ ផលិតផលសូត្រចិនទទួលបាននូវការគាំទ្រពីមន្ត្រីកម្ពុជា។ ប្រទេសកម្ពុជាក៏មានផលិតផលល្អៗជាច្រើននាំទៅប្រទេសចិនផងដែរដូចជាសត្វស្លាបច្រើនប្រភេទ សត្វពាហនៈ ភ្លុកដំរី ស្នែងរមាស ក្រមួនឃ្មុំ ខ្លឹមចន្ទន៍ក្រស្នា ក្រវាញ ជ័រចុង ប្រេងសម្លាងជាដើម សុទ្ធតែទទួលបានការ

---

(១៥) www.cen.com.kh/Culture

ស្រឡាញ់ចូលចិត្តពីប្រជាជនចិនសម័យនោះ(១៦)។

## ២.១.១០-ការយល់ច្រឡំរបស់ជនជាតិចិន

នៅក្នុងកំណត់ត្រានេះ ទោះបីជាលោក **ជីវតាក្វាន់** បានសរសេរយ៉ាងក្បោះក្បាយពីប្រពៃណីទំនៀមទម្លាប់របស់ខ្មែរយ៉ាងណាក៏ដោយ ក៏លោកបានសារភាពដោយត្រង់ៗថារឿងរ៉ាវមួយចំនួនធំ លោកមិនបានដឹងច្បាស់លាស់ដែរ ដោយហេតុថាអ្នកស្រុកមិនឱ្យជនជាតិចិនចូលមើលឡើយដូចករណី **ពិធីបើកព្រហ្មចារី** ជាដើម។ ខាងក្រោមនេះជាការបង្ហាញពីអត្ថន័យនៃពិធីបើកព្រហ្មចារីនៅក្នុងកំណត់ត្រារបស់លោក **ជីវតាក្វាន់** ៖

«គ្រួសារដែលមានទ្រព្យសម្បត្តិគួរសម ត្រូវធ្វើពិធីនេះចំពោះកូនស្រីគេពីអាយុ៧ ដល់ ៩ ឆ្នាំ។ រីឯគ្រួសារក្រីក្រវិញ គេអាចពន្យារពេលដោយប្រារព្ធពិធីនេះពេលដែលក្មេងស្រីនោះមានអាយុ១១ឆ្នាំ ហើយអ្នកដែលធ្វើពិធីនេះបាន គឺមានតែព្រះភិក្ខុសង្ឃឬតាបសដែលជាអរិយបុគ្គល ពោលគឺជាទីពឹងនិងជាទីគោរពសក្ការៈរបស់ប្រជាជនខ្មែរនាសម័យនោះ។ មុននឹងប្រារព្ធពិធីដ៏សំខាន់នេះ ឪពុកម្ដាយនៃក្មេងត្រូវអញ្ជើញទៅនិមន្តព្រះភិក្ខុសង្ឃឬតាបសដែលនៅក្នុងវត្តអារាម ឬអាស្រមដែលខ្លួនរាប់អាន និងគោរពទុកចិត្តប្រតិបត្តិតាមនោះ។ តាមទំនៀមទម្លាប់សម័យនោះ ព្រះភិក្ខុ ឬតាបសនាជំនាន់នោះមួយឆ្នាំអាចធ្វើពិធីនេះតែមួយដង ហើយសម្រាប់ក្មេងស្រីតែម្នាក់ប៉ុណ្ណោះ។ ដើម្បីបំពេញពិធីដ៏សំខាន់នេះ ឪពុកម្ដាយនៃកូនស្រីត្រូវជម្រាបឱ្យភ្នាក់ងាររាជការដឹងមុនចំនួនមួយខែមុន ឬយ៉ាងហោចណាស់ក៏កន្លះ


真臘風土記
總敘
周達觀撰
真臘國或稱占臘其國自稱曰甘孛智今聖朝按西番經名其國曰澉浦只蓋亦甘
孛智之近音也自溫州開洋行丁未針歷閩廣海外諸州港口過七洲洋經交趾洋
到占城又自占城順風可半月到真蒲乃其境也又自真蒲行坤申針過崑崙洋入
港港凡數十惟第四港可入其餘悉以沙淺故不通巨舟然而彌望皆修藤古木黄
沙白葦倉卒未易辨認故舟人以尋港為難事自港口北行順水可半月抵其地曰
查南乃其屬郡也又自查南換小舟順水可十餘日過半路村佛村渡淡洋可抵其
地曰干傍取城五十里按諸番志稱其地廣七千里其國北抵占城半月路西南距
暹羅半月程南距番禺十日程其東則大海也舊為通商來往之國聖朝誕膺天命
奄有四海唆都元帥之置省占城也嘗遣一虎符百戶一金牌千戶同到本國竟為
拘執不返元貞之乙未六月聖天子遣使招諭俾余從行以次年丙申二月離明州
二十日自溫州港口開洋三月十五日抵占城中途逆風不利秋七月始至遂得臣
真臘風土記

កំណត់ត្រារបស់លោក ជីវតាក្វាន់
(ប្រភព ៖ www.epochtimes.com)

---

(១៦) វូ គ័ងហ្វ៊ួ ៖ **ទំនាក់ទំនងរបស់រជ្ជកាលយាន និងប្រទេសចេនឡា** -ដ.ឯ.ម- ទំព័រទី១១៨។

ខែមុនដែរ។ អាជ្ញាធរនឹងឱ្យទៀនធំមួយដើមដោយលាក់ឬក្រីទៀននោះជាស្រេច។ ដល់ពេលប្រគល់ គេក៏ដុតទៀននោះហើយបើទៀននោះឆេះដល់ត្រង់កន្លែងលាក់ ឬកន្លែងក្រីហើយអាចារ្យក៏ឱ្យផ្តើមដំណើរការបើកព្រហ្មចារី។ មនុស្សដែលរស់នៅក្នុងបរមរាជវាំង ឬគហបតី គេធ្វើអំណោយជាអង្ករកំណាត់ព្រៃ ស្រា ម្លូរាប់រយហាប់ ហើយបើប្រៀបទៅនឹងប្រាក់ស្រុកចិនវិញវាស្មើនឹង២០០តម្លឹង។ នៅពេលយប់គេបានធ្វើពិធីជប់លៀងធំមួយ ដោយមានក្រុមតូរ្យតន្ត្រីកំដរទៀតផង ដោយមានញាតិមិត្តជិតឆ្ងាយមកចូលរួមយ៉ាងកុះករ ដើម្បីអបអរសាទរចំពោះពិធីនោះដែលត្រូវប្រព្រឹត្តតែមួយដងគត់ក្នុងជីវិតរបស់ស្ត្រី។ នៅមុខផ្ទះគេតរោងខ្ពស់។ លើរានគេតាំងរូបតុក្កតាតំណាងមនុស្សនិងសត្វធ្វើអំពីដីដុតតាមលទ្ធភាពរបស់គ្រួសារ ហើយជួនកាលក៏គ្មានដែរ។ ពិធីនេះត្រូវធ្វើឡើងគ្រប់៧យប់៧ថ្ងៃ បន្ទាប់មកម្ចាស់ផ្ទះក៏រើវត្ថុទាំងអស់នោះដាក់ស្នែងដាក់អម្រែក។ នៅពេលព្រលប់ គេដើរជាក្បួនទៅកាន់វត្ត ដើម្បីនិមន្តព្រះភិក្ខុដោយមានទាំងក្រុមតន្ត្រីចូលរួមដំណើរទៀតផង។ ចំពោះការរៀបចំពិធីបុណ្យ ម្ចាស់ផ្ទះយកកំណាត់ព្រៃដែលមានពណ៌ចម្រុះផ្សេងមកហ៊ុមព័ទ្ធរោងឈើពីរខ្នង គឺមួយខ្នងសម្រាប់ក្មេងស្រី ហើយមួយខ្នងទៀត សម្រាប់ប្រគេនទៅព្រះភិក្ខុសង្ឃ។ ក្នុងខណៈដែលព្រះភិក្ខុសង្ឃនិងក្មេងស្រីបានចូលទៅក្នុងបន្ទប់ ព្រះសង្ឃក៏យកដៃរបស់ព្រះអង្គទៅទម្លុះព្រហ្មចារីរបស់ក្មេងស្រីនោះទៅ។ បន្ទាប់មកទៀតព្រះអង្គក៏យកជាតិរំអិលព្រហ្មចារីទៅដាក់ក្នុងស្រា ដើម្បីយកជូនមាតាបិតា ឬ ញាតិញោមនៃក្មេងស្រី។ មានមនុស្សខ្លះបានពោលថាគេយកស្រានោះមកលាបថ្ងាស។ អ្នកខ្លះទៀតក៏ថាព្រះភិក្ខុសង្ឃមិនបានយកម្រាមដៃទៅទម្លុះព្រហ្មចារីទេ ក៏ប៉ុន្តែព្រះអង្គបានរួមសង្វាស (សេពកាម) ជាមួយក្មេងស្រីនោះផ្ទាល់តែម្តង។ លុះព្រឹកឡើងពេលព្រះអាទិត្យរះ គេនាំគ្នាយកគ្រែស្នែងអម្រែករែកកញ្ជើល្អីដាក់របស់របរ និងតន្ត្រីដង្ហែព្រះភិក្ខុសង្ឃនិមន្តទៅវត្តវិញ។ បន្ទាប់មក ឪពុកម្តាយបានយកសំពត់សមកលោះកូនស្រីពីសំណាក់ព្រះភិក្ខុសង្ឃនោះវិញ។ បើមិនដូច្នោះទេ ក្មេងស្រីនោះនឹងក្លាយជាកម្មសិទ្ធិរបស់ព្រះភិក្ខុនោះ ហើយមិនអាចទៅរៀបការជាមួយនឹងអ្នកណាបានទេ។ គួរបញ្ជាក់ថាមុនប្រារព្ធធ្វើ **ពិធីបើកព្រហ្មចារី** ក្មេងស្រីនោះដេកនៅជាមួយឪពុកម្តាយ លុះក្រោយពីប្រារព្ធពិធីនេះរួចត្រូវដេកកន្លែងណាមួយផ្សេងក្នុងផ្ទះក៏បានតាមតែចិត្តរបស់នាងចង់»។

បើតាមលោកបណ្ឌិត **មីសែល ត្រាណេ** បានអះអាងថា **ពិធីបើកព្រហ្មចារី** គឺពិធីឆ្លង ឬជាប្រពៃណីចម្លងមួយធ្វើឡើងសម្រាប់ចម្លងមនុស្សពីវ័យកុមារភាពដល់វ័យពេញក្រមុំ។ តាមពិតទៅពិធីនេះ ពុំទាន់មានលក្ខណៈពេញលេញនៅឡើយទេ ព្រោះវាគ្រាន់តែជាដំណាក់កាល

ដំបូងបង្អស់តែប៉ុណ្ណោះសម្រាប់ក្មេងស្រីខ្មែរមុនពេលរៀបអាពាហ៍ពិពាហ៍ដែលជាដំណាក់កាលដ៏សំខាន់បំផុតរបស់ស្ត្រីខ្មែរ។ ពិធីនេះឆ្លុះបញ្ចាំងឱ្យឃើញថាចាប់ពីថ្ងៃនេះទៅនាងមានមុខងារតួនាទីថ្មីនៅក្នុងសង្គម ពោលគឺនាងត្រូវបំពេញកាតព្វកិច្ចមួយចំនួនថ្មីៗខុសពីក្មេងស្រីដទៃទៀត។ ការពិនិត្យប្រពៃណីខ្មែរសតវត្សទី១៩ និងដើមសតវត្សទី២០ ដូចជា **ពិធីចូលម្លប់ ចេញម្លប់** អាចបញ្ជាក់ឱ្យយើងឃើញទំនាក់ទំនងផ្នែកនិមិត្តរូបយ៉ាងជិតស្និទ្ធរវាងពិធីនេះ និងពិធីបើកព្រហ្មចារីនាសម័យអង្គរ។ ម្យ៉ាងទៀត ដោយសារសង្គមខ្មែរបុរាណជាសង្គមដែលមានតម្លៃ ឬប្រកាន់សីលធម៌ សច្ចធម៌ និងភាពល្អបរិសុទ្ធយ៉ាងខ្ពស់។ ចំពោះទស្សនៈដែលយល់ថាព្រះសង្ឃសេពកាមជាមួយក្មេង គឺជាពាក្យចចាមអារ៉ាមដែលលោក **ជីវតាក្វាន់** បានពោលពេលដែលគាត់បានបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា ព្រោះលោកមិនបានដឹងច្បាស់ និងបានមើលឃើញដោយផ្ទាល់ភ្នែកនោះឡើយ។

គួរបញ្ជាក់ផងដែរថា នៅក្នុងកំណត់ហេតុរបស់លោក **ជីវតាក្វាន់** ដែលមាន៨.៥០០តួអក្សរ ក្នុងនោះអក្សរដែលពិពណ៌នាអំពីស្ត្រីខ្មែរមានចំនួន១.៨៥០តួ។ នេះជាការបង្ហាញឱ្យឃើញថាលោកមានចំណាប់អារម្មណ៍ទៅលើស្ត្រីភេទប្រទេសចេនឡា។ លោកបានពោលថាស្ត្រីខ្មែរជាស្ត្រីល្មោភកាម ព្រោះក្រោយពេលដែលសម្រាលកូនហើយមួយថ្ងៃឬពីថ្ងៃប៉ុណ្ណោះ គេក៏រួមដំណេកជាមួយប្តី។ បើប្តីនោះបំពេញចំណង់ខ្លួនមិនបានទេ គេនឹងបោះបង់ប្តីចោល។ ប្រសិនប្តីនោះមានធុរៈទៅស្រុកឆ្ងាយអស់រយៈពេលច្រើនយប់( ចាប់ពីដប់យប់ឡើងទៅ ) ច្បាស់ជាត្រូវប្រពន្ធស្តីឱ្យថា **«ខ្ញុំមិនមែនខ្មោចទេ តើឱ្យខ្ញុំដេកម្នាក់ឯងម្តេចនឹងបាន ?»** ស្ត្រីខ្មែរដែលសម្រាលកូនរួច បានយកបាយក្តៅប្រឡាក់អំបិលញាត់ចូលក្នុងទ្វារមាស ដើម្បីធ្វើឱ្យមានសុខភាពល្អនិងធ្វើឱ្យទ្វារមាសរួមតូច(១៧)។

ដោយសារហេតុនេះហើយ ទើបបង្កើតឱ្យមានកំហុសអានផ្នែកវប្បធម៌ ដែលនេះគឺមិនអាចជៀសវាងបានឡើយ ហើយដែលស្ថិតក្នុងវិចារណញាណ។ ហើយបើសិនជានិយាយនៅលើអត្ថន័យណាមួយ លោក **ជីវតាក្វាន់** ក្នុងនាមជាអ្នកខាងក្រៅ បទពិសោធនិងការសង្កេតរបស់គាត់ទៅលើសាសនាគ្រាន់តែអាចថាសង្កេតមើលពីចម្ងាយ ឬក៏ស្មានគំនិតដែលមើលឃើញតែរូបរាងខាងក្រៅត្រួសៗតែប៉ុណ្ណោះ។ នៅក្នុងទំនៀមទម្លាប់របស់ជនជាតិចិនដែលទទួលរងឥទ្ធិពលពីវប្បធម៌លទ្ធិខុងជឺ ភេទនិងទំនាក់ទំនងផ្លូវភេទ គឺត្រូវបានរុំព័ទ្ធដោយស្រទាប់

---

(១៧) អ៊ី តុងលីង ៖ **ទិដ្ឋភាពប្រទេសកម្ពុជាក្រោមក្រសៃភ្នែកអ្នកកាន់លទ្ធិខុងជឺនៅក្នុងសន្និសីទអន្តរជាតិលើកទី១ ស្តីពីទំនាក់ទំនងកម្ពុជា-ចិននាសម័យចេនឡានិងអង្គរ,** រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១ ទំព័រទី១២៥។

គុណធម៌មួយជាន់ហើយមួយជាន់ទៀតយ៉ាងតឹងរ៉ឹង ការពិភាក្សាពីរឿងភេទដោយចំហជាសាធារណៈនោះ នឹងត្រូវបានមនុស្សទាំងឡាយចាត់ទុកជារឿងថោកទាបខុសសីលធម៌ខ្លាំងណាស់។ ដូចនេះ ពេលបានជួបប្រទះភាពននោលគោករបស់ជនជាតិខ្មែរនៅទីសាធារណៈ ក្នុងនាមលោក **ជីវតាក្វាន់** ដែលជាអ្នកឈរមើលនៅម្ខាង គឺមិនអាចស្ងប់ចិត្ត ស្ងប់អារម្មណ៍បានឡើយ។ ការនឹកឃើញនូវគុណធម៌ផ្ទុយផង់របស់ជនជាតិខ្លួន ហើយមើលស្រោលទៅលើដៃគូម្ខាងទៀត បានធ្វើឱ្យលោក **ជីវតាក្វាន់** មានការដិតដាមជាប់ក្នុងខួរក្បាលគាត់យ៉ាងខ្លាំងពីស្ត្រីខ្មែរនោះគឺ **«ស្ត្រីកាមតណ្ហាក្រាស់»** និង **«ប្រុសនិងស្រីមុជទឹកស្រោតជាមួយគ្នា»**(១៨)។



រូបគំនូរលោក ជីវតាក្វាន់

(ប្រភព ៖ www.devata.org)




ផែនទីដំណើររបស់លោក ជីវតាក្វាន់ មកកាន់រាជធានីអង្គរ

(ប្រភព ៖ www.skhlkyss.edu.hk)

---

(១៨) លី នីងនីង ៖ **ទិដ្ឋភាពប្រទេសកម្ពុជាក្រោមក្រសែភ្នែកអ្នកកាន់លទ្ធិខុងជឺនៅក្នុងសន្និសីទអន្តរជាតិលើកទី១ ស្តីពីទំនាក់ទំនងកម្ពុជា-ចិននាសម័យចេនឡានិងអង្គរ**, រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១ ទំព័រទី៨៦-៨៧។

## ២.២-នយោបាយ

### ២.២.១-កិច្ចគាំទ្រនយោបាយចិនតែមួយ

#### ក-ជនជាតិចិនមកកាន់សមុទ្រចិនខាងត្បូង

ក្នុងដំណើរមកកាន់សមុទ្រចិនខាងត្បូង ជនជាតិចិនគឺសំដៅមកហ្វូណន។ វត្តមានរបស់លោក **កាំងថៃ** និងលោក **ជូយីង**(រាជទូតនគររ៉ូវរបស់ចិនក្នុងសម័យសាមកុក)នៅលើទឹកដីហ្វូណនគឺជាការទាញយកកម្ពុជាចូលទៅក្នុងសង្គ្រាមនៅក្នុងប្រទេសចិន។ ក្នុងស្មារតីគាំទ្រនយោបាយចិនតែមួយ តាមរយៈការបង្រួបបង្រួមជាតិដោយសន្តិវិធី ព្រះមហាក្សត្រខ្មែរមិនបានបញ្ជូនទ័ព ដើម្បីជួយច្បាំងនគររ៉ូទេ បែរជាឱ្យក្រុមតន្ត្រីខ្មែរទៅប្រគំថ្វាយព្រះមហាក្សត្រនគររ៉ូ។ តន្ត្រីជាភាសាសាកល និងជាភាសាដែលនាំឱ្យមនុស្សអស់កង្វល់និងទទួលបានភាពរីករាយ។ ការបញ្ជូនតន្ត្រីទៅនគររ៉ូ គឺជាការបង្ហាញយ៉ាងច្បាស់អំពីទស្សនវិជ្ជាសន្តិភាពរបស់ព្រះមហាក្សត្រខ្មែរ ក្នុងការបញ្ចប់សង្គ្រាមតាមរយៈការចរចានិងអហិង្សាធម៌។ នេះជាទស្សនវិជ្ជានយោបាយ **ឈ្នះ-ឈ្នះ** របស់ខ្មែរ ដោយមិនយកនគរណាមួយរបស់ចិនជាសត្រូវ តែគាំទ្រជាប់ជានិច្ចចំពោះការសម្របសម្រួលផ្ទៃកនយោបាយរបស់ប្រទេសចិនដោយផ្អែកលើបញ្ញត្តិ **«ចិនតែមួយ»**។

#### ខ-កំណត់ត្រារបស់ចិន

**ជីវតាក្វាន់** ជាជនជាតិចិនមួយរូបរស់នៅក្នុងរជ្ជកាល **យាន** បានចូលរួមជាមួយប្រតិភូចិនធ្វើទស្សនកិច្ចនៅប្រទេសខ្មែរនៅឆ្នាំ១២៩៥។ លោកបានបន្សល់ទុកនូវកំណត់ហេតុមួយដែលមានលក្ខណៈជាប្រវត្តិសាស្ត្រ ស្តីពីប្រទេសខ្មែរយើងក្នុងសម័យនោះ។ ឯកសាររបស់លោក **ជីវតាក្វាន់** មានឈ្មោះថា «ប្រពៃណីរបស់អ្នកស្រុកចេនឡា» [១៩]។ ចំពោះជនជាតិចិននាសតវត្សទី១៣ ពាក្យ **ចេនឡា** នេះកំណត់ហៅប្រទេសកម្ពុជា ។

ក្នុងសម័យនេះ បើយោងលើកំណត់ហេតុចិននិងបុរាណវត្ថុ យើងដឹងថាទំនាក់ទំនងខ្មែរ- ចិនក៏នៅរក្សាតួនាទីរបស់ខ្លួនដូចសម័យមុនៗដដែល ទោះជាជួនកាលខ្មែរស្ថិតក្នុងស្ថានភាព

---

(១៩) សូមជម្រាបថាកំណត់ហេតុរបស់ **ជីវតាក្វាន់** បានត្រូវប្រែពីភាសាចិនមកជាភាសាបារាំង ដោយលោក **ប៉ូល ប៉េល្លីយ៉ូត** ដែលជាអ្នកភាសាវិទូផ្នែកភាសាសាស្ត្រចិន។ អត្ថបទនេះត្រូវបានអ្នកនិពន្ធយកមកប្រែនៅឆ្នាំ១៩០២ ហើយកែសម្រួលនៅឆ្នាំ១៩៤៩ គឺជាឆ្នាំដែលលោកបានទទួលអនិច្ចកម្ម។ ឯកសារនេះត្រូវបានគេយកទៅបោះពុម្ព ឯប្រទេសបារាំងនៅឆ្នាំ១៩៥១។

លំបាកលំបិនដែលបណ្តាលដោយភ្លើងសង្គ្រាមក៏ដោយ។ ក្នុងន័យនេះ យើងឯកភាពជាមួយអ្នកប្រាជ្ញមួយចំនួនដែលបានពោលថាទំនាក់ទំនងដ៏ប្រពៃទាំងនោះហើយ គឺជាកត្តាចម្បងក្នុងការអភិវឌ្ឍប្រទេសជាតិកម្ពុជាប្រកបដោយចីរភាព។ ដោយកត្តានេះក្នុងអារម្មណ៍របស់យើងបាននាំមកភាពរុងរឿងថ្កើងថ្កានដែលបានស្តែងតាមរយៈមូលហេតុសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។ សម័យមហានគរ ប្រទេសកម្ពុជាមានឈ្មោះបោះសំឡេងយ៉ាងខ្ទរខ្ទារទូទាំងភូមិភាគអាស៊ីអាគ្នេយ៍ ដោយបានគ្រប់គ្រងដឹកនាំដោយព្រះមហាក្សត្រដ៏ខ្លាំងពូកែជាច្រើនអង្គដែលធ្វើឱ្យប្រទេសជិតខាងស្ញប់ស្ញែងកោតខ្លាច។ ហេតុនេះហើយ ទើបបានជាវប្បធម៌ខ្មែរបានឈានដល់កម្រិតខ្ពស់ផុតកំពូល។ ប្រភពឯកសារជាច្រើនដោយឡែកកំណត់ហេតុចិនបានឱ្យដឹងថាព្រំប្រទល់ដែននៃប្រទេសកម្ពុជាខាងត្បូងទល់នឹងម៉ាឡាយូ(ម៉ាឡេស៊ី)ខាងជើងលាតសន្ធឹងទល់នឹងនគរចម្ប៉ាឬលិនយី ខាងកើតសមុទ្រ និងខាងលិចបូកាន ឬប្រទេសភូមា។ វឌ្ឍនភាពនិងកិត្យានុភាពដ៏រឹងមាំនៃប្រទេសកម្ពុជាបុរាណក៏ត្រូវបានគូសបញ្ជាក់យ៉ាងជាក់ច្បាស់តាមរយៈសំណង់ស្ថាបត្យកម្មជាច្រើន ដូចជាប្រាសាទអង្គរវត្ត និងប្រាសាទដទៃៗឯទៀត ដែលត្រូវបានកសាងឡើងដោយ **ព្រះបាទសុរិយាវរ្ម័នទី២** ជាសក្ខីភាពស្រាប់។ សូមរំឭកជាព័ត៌មានថាព្រះកិត្តិនាមនិងភាពល្បីល្បាញនៃស្តេចអង្គនេះត្រូវបានចៅអធិរាជចិនថ្វាយឋានន្តរស័ក្តិយ៉ាងខ្ពង់ខ្ពស់បំផុត ជាភាសាចិនថា **គិនពីងពិនចេន** មានន័យថា **កម្រតេង**។ ម្យ៉ាងវិញទៀតដូចសម័យមុនៗដែរ **ព្រះបាទសុរិយាវរ្ម័ន** ទ្រង់ក៏បានពង្រឹងសម្ព័ន្ធភាពតាមផ្លូវទូតជាមួយប្រទេសចិន ជាហេតុនាំឱ្យចិនគាំទ្រគោលការណ៍នយោបាយរបស់រាជរដ្ឋាភិបាលខ្មែរក្នុងការអភិវឌ្ឍប្រទេស ជាតិក៏ដូចក្នុងការការពារបូរណភាពទឹកដីដែរ។ ដោយហេតុថា ក្នុងរាជ្យរបស់ស្តេចអង្គនេះដែលបានឡើងសោយរាជសម្បត្តិ នៅឆ្នាំ១១១៣នៃគ្រិស្តសករាជ ប្រទេសកម្ពុជាបានរងការវាយលុកលុយរបស់ពីប្រទេសភូមា នៅហរិបុញ្ជ័យ នគរចម្ប៉ានិងដាយវៀត។ បើសំអាងលើឯកសារចិន យើងដឹងថាទោះជាសង្គ្រាមរបស់ទ្រង់ធ្វើឡើងនោះ ដើម្បីបង្ក្រាបឬរុញច្រានបច្ចាមិត្របានជួបប្រទះភាពលំបាកលំបិនគ្រប់បែបយ៉ាងក្តី ក៏ប៉ុន្តែអធិបតេយ្យភាពនៃដែនដីខ្មែរត្រូវបានរក្សាបានយ៉ាងតឹងណែនទាំងស្រុងនៅឡើយ[២០]។

ក៏ប៉ុន្តែ អ្វីដែលសំខាន់បំផុតសម្រាប់យើងនោះគឺក្នុងលោកនេះ គ្មានប្រទេសណាដែល

(២០) មីសែល ត្រាណេ ៖ **៥.០០០ឆ្នាំនៃទំនាក់ទំនងខ្មែរ-ចិន នៅក្នុងសន្និសីទអន្តរជាតិលើកទី១ ស្តីពីទំនាក់ទំនងកម្ពុជា-ចិននាសម័យចេនឡានិងអង្គរ**, រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១ ទំព័រទី៧៥-៧៧។

ប្រមុខដឹកនាំខិតខំប្រមូលផ្ដុំផ្ដុំនូវព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពនៃប្រទេសជិតខាងរបស់ខ្លួនដូច ប្រទេសចិនឡើយ។ ហើយកិច្ចការដ៏មានប្រយោជន៍នេះ វាមិនគ្រាន់តែផ្ដល់ចំពោះអាជ្ញាធរចិន នូវភាពងាយស្រួលក្នុងវិស័យសេដ្ឋកិច្ច ក៏ប៉ុន្តែទន្ទឹមនឹងនេះ **សំណេរចិនបុរាណគឺជាប្រភពមូលដ្ឋាននៃប្រវត្តិសាស្ត្ររបស់ជនជាតិខ្មែរទាំងមូលផងដែរ** ។

ជាទូទៅ អ្នកស្រាវជ្រាវទូទាំងពិភពលោក បានទទួលស្គាល់ហើយឱ្យតម្លៃយ៉ាងខ្ពស់បំផុតថាការចងក្រងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ត្រូវពឹងផ្អែកជាចម្បងទៅលើសំណេរចិន ដែលមានកត់ត្រាយ៉ាងល្អិតល្អន់នៅក្នុងកាលប្បវត្តិចិនតាមសន្តតិវង្សជាបន្តបន្ទាប់។ ហើយតាមរយៈប្រភពឯកសារនេះ ដែលត្រូវបានពង្រឹង ឬបំពេញបន្ថែមដោយប្រភពសិលាចារឹកខ្មែរ យើងបានកាត់បន្ថយនូវភាពអច្ឆរិយៈដែលមានក្នុង **ព្រះរាជពង្សាវតារខ្មែរ** ដោយផ្ដល់ចំណេះដឹងខាងប្រវត្តិសាស្ត្រយ៉ាងសមស្របនឹងព្រឹត្តិការណ៍ជាក់ស្ដែង ដែលកន្លងមកបានកើតមានឡើងក្នុងអតីតកាល។

### ២.២.២-កិច្ចការពារជនជាតិចិន

កំណត់ត្រារបស់លោក **ជីវតាក្វាន់** ជាត្រីវិស័យប្រវត្តិសាស្ត្រមួយយ៉ាងសំខាន់ ដោយបានកត់ត្រារឿងរ៉ាវនានាពីសង្គមខ្មែរនាសម័យអង្គរ។ សូម្បីតែពាក្យពេចន៍មួយចំនួនក៏លោកបានកត់ត្រាយ៉ាងពិស្តារផងដែរដូចជាឃ្លា **«មិនដឹងភាសា»** និង **«ប្រមាត់ប្រមង់»** ជាដើម។

**ប្រមាត់ប្រមង់** តែងត្រូវបានអ្នកស្រុកប្រើពេលមានមានអសន្តិសុខឬមានអាសន្ន។ យើងធ្លាប់ឮចាស់ៗដែលរស់នៅតាមស្រុកភូមិនិយាយទៅកាន់កូនក្មេងថា ៖ «កុំចេញទៅក្រៅតិចគេចាប់ញាត់បាវយកទៅឱ្យប្រមាត់ប្រមង់»។ ជនជាតិខ្មែរមួយចំនួនតែងមានជំនឿថាប្រមាត់ជាថ្នាំដ៏ពិសិដ្ឋកែរោគមួយចំនួន ដែលជាហេតុធ្វើឱ្យបុគ្គលអសីលធម៌មួយចំនួនសម្លាប់មនុស្សដើម្បីយកប្រមាត់។ លោក **ជីវតាក្វាន់** បានកត់ត្រាថា ៖ «កាលពីមុននេះតែដល់ខែទី៨ គេតែងធ្វើការចាប់មនុស្សយកប្រមាត់ ពីព្រោះស្ដេចក្រុងចាមក្នុងមួយឆ្នាំគេសុំយកប្រមាត់មនុស្សមួយថូដែលមានចំនួនរាប់ពាន់។ នៅក្នុងពេលយប់ គេចាត់ពួកអ្នកយកប្រមាត់( ប្រមាត់ប្រមង់ ) ដើរទៅតាមផ្លូវនានាក្នុងទីក្រុងនិងក្នុងភូមិ។ បើប្រទះមនុស្សណាដើរក្នុងពេលយប់ស្ងាត់នោះ គេចាប់យកខ្សែចងក្បាលឱ្យជាប់ ហើយយកកូនកាំបិតចាក់ក្រោមភ្លៀកខាងស្ដាំខ្វេះយកប្រមាត់ដាក់ក្នុងថូ លុះត្រាតែបានពេញចំនួនទើបគេយកទៅថ្វាយស្ដេចក្រុងចាម។ ប៉ុន្តែគេមិនយកប្រមាត់ជនជាតិចិនទេ ពីព្រោះមានកាលឆ្នាំមួយនោះ គេយកប្រមាត់ជនជាតិចិនលាយនឹងគេ

ក៏បណ្ដាលឱ្យស្អុយរលួយខូចប្រមាត់នៅក្នុងថូលែងប្រើការបានទាំងអស់។ ក្នុងន័យនេះដើម្បីការពារជនជាតិចិន**ប្រឌិតរឿងកុហកមួយដែលមិនទំនងមកបន្លំភ្នែកស្ដេចក្រុងចាមដើម្បីឱ្យបានសម្រេចគោលបំណង។** ដោយសារតែហេតុនេះហើយប្រទេសចេនឡាមានតំបន់ខ្លះស្ទើរតែបានក្លាយទៅជាតំបន់ជនជាតិចិន»។

**មិនដឹងភាសា** ជាពាក្យបីម៉ាត់ដែលគេបានជួបប្រទះនៅក្នុងកំណត់ត្រារបស់លោក **ជីវតាក្វាន់** ដែលនិយាយសំដៅទៅជនជាតិចិនរស់នៅក្នុងប្រទេសកម្ពុជា ដែលពុំបានអនុវត្តប្រតិបត្តិតាមទំនៀមទម្លាប់ដូចខ្មែរ។ ពាក្យ **«ភាសា»** នៅទីនេះពុំមែនសំដៅទៅលើភាសាឆ្លើយឆ្លងដូចគេស្មាននោះឡើយ ហើយម្យ៉ាងទៀត ពាក្យនេះបានបាត់ពីពាក្យពេចន៍ឃ្លាប្រយោគរបស់ខ្មែរយើងសព្វថ្ងៃទៅហើយ។ ឃ្លាប្រយោគ **«មិនដឹងភាសា»** ខាងលើនេះមានន័យដូចពាក្យថៃ **«ម៉ៃលូផាសា»** ដែលគេប្រើមកដល់សព្វថ្ងៃនេះដែរ។ វត្តមានរបស់ឃ្លាប្រយោគនេះក្នុងពាក្យខ្មែរសុរិន្ទ ខ្មែរបុរីរម្យ ដូចជា «បរទេសគោឱ្យដឹងភាសា» «អង្គុយឱ្យដឹងភាសា» «កូននេះដឹងភាសាណាស់» «និយាយឱ្យដឹងភាសាផង»។ល។ យ៉ាងណាមិញវត្តមានរបស់ឃ្លា «មិនដឹងភាសា ឬ ដឹងភាសា» នៅក្នុងកំណត់ហេតុរបស់ **ជីវតាក្វាន់** និងការណ៍ដែលខ្មែររស់នៅស្រុកថៃនៅនិយមប្រើប្រាស់នោះសឱ្យឃើញថាជនជាតិសៀមបានខ្ចីឃ្លាប្រយោគនេះពីខ្មែរ នាសម័យបុរាណយ៉ាងប្រាកដ ពោលគឺពេលដែលពួកគេទើបចុះពីប្រទេសចិន ហើយបានតាំងលំនៅដ្ឋាននៅក្នុងខេត្តសុខោទ័យនាសតវត្សទី១៣នៃគ្រិស្ដសករាជ។ បុរាណវិទូចាងសៀកបានកត់ត្រាថាប្រទេសចេនឡានៅពេលនោះមាន «ឈើជារបងព្រំដែន»។ គេយកឈើធ្វើជាទីក្រុងគឺជាកន្លែងដែលជនជាតិចិនស្នាក់អាស្រ័យនៅ។ អ្នកស្រុកក្នុងតំបន់នេះស្លូតបូតទៀងត្រង់ណាស់ គេមិនដែលបង្កទំនាស់ជាមួយជនជាតិចិនឡើយព្រោះគេយល់ឃើញថាជនជាតិចិនមិនយល់ភាសារបស់អ្នកស្រុក។ ប្រសិនបើមានការជួបទំនាស់ម្ដងម្កាលគេឱ្យជនជាតិចិនរកអ្នកចេះភាសាមកដោះស្រាយវិវាទដោយខ្លួនឯង(២១)។

---

(២១) វ៉ង់ ស៊ានមាវ ៖ **រាប់ពាន់ឆ្នាំទំនាក់ទំនងល្អកម្ពុជា-ចិន សុខដុមរមនា នៅក្នុងសន្និសីទអន្តរជាតិលើកទី១ ស្ដីពីទំនាក់ទំនងកម្ពុជា-ចិននាសម័យចេនឡានិងអង្គរ**, រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១។

### ២.២.៣-ការរារាំងរបស់អាណ្ណាម និង ចម្ប៉ា

តាមការកត់ត្រារបស់សៀវភៅ **«កំណត់ត្រាយានសឺសឺកជួ»** នៅឆ្នាំ១២៧៥ ព្រះមហាក្សត្រចិន **ហ៊្វូពិលាក** បានសំណូមពរឱ្យព្រះមហាក្សត្រយួន ព្រះនាម **ឈិនគួងពីង** ដាច់ខាតត្រូវធ្វើឱ្យបានកិច្ចការ៦យ៉ាងគឺ ៖ **ទី១**-ស្តេចនគរអាណ្ណាមត្រូវមកចូលគាល់ **ហ៊្វូពិលាក** ដោយផ្ទាល់ **ទី២**-ត្រូវយកប្អូនប្រុសឬក៏កូនប្រុសមកធ្វើជាចំណាប់ខ្មាំង **ទី៣**-ត្រូវរាយការណ៍ពីចំនួនប្រជាជន **ទី៤**-ត្រូវនាំទ័ពច្បាំងពេលមានសង្គ្រាម **ទី៥**-ត្រូវបង់ពន្ធ និង**ទី៦**-ត្រូវបង្កើតរចនាសម្ព័ន្ធដើម្បីមកគ្រប់គ្រងតំបន់នោះ។ ប៉ុន្តែស្តេចយួនមិនបានគោរពឡើយ ដោយយកលេសថាខ្លួនមានឧបសគ្គដោយសារតែ **នគរចេនឡា**។ តាមរយៈឧបាយកលនេះ **ហ៊្វូពិលាក** បានបញ្ជូនទ័ពជួយនគរអាណ្ណាមវាយប្រហារនគរចេនឡា។ ក្នុងន័យនេះ ទំនាក់ទំនងរវាងកម្ពុជា និងចិន គឺត្រូវបានបង្ខាំងដោយប្រទេសអាណ្ណាម ពីព្រោះ **ហ៊្វូពិលាក** បានស្តាប់និងជឿតែសម្តីរបស់ **ឈិនគួងពីង** ប៉ុណ្ណោះ។ **ឈិនគួងពីង** បានលួងលោមរជ្ជកាលយានហើយពង្រីកកម្លាំងស្ងាត់ៗដើម្បីឈ្លានពានប្រទេសជិតខាងជាបន្តបន្ទាប់ និងរិះរកមធ្យោបាយប្រើប្រាស់កម្លាំងទ័ពរបស់រជ្ជកាលយាន ដើម្បីសម្រេចគោលបំណងរបស់គេ ដើម្បីធ្វើឱ្យនគរចេនឡាដែលមានព្រំប្រទល់ជិតខាងទទួលរងនូវការខាតបង់យ៉ាងធំ[២២]។

ក្រៅពីអាណ្ណាម នគរចម្ប៉ាជាប្រទេសទី២ដែលរំខានទំនាក់ទំនងចេនឡា និងរជ្ជកាលយាន។ លោក **ជីវតាក្វាន់** បានអះអាងថាសេនាប្រមុខ **សួទូ** ដែលមានស្លាកបញ្ជាទ័ពអាចបញ្ជាទ័ព១.០០០នាក់ បានធ្វើដំណើរមកទំនាក់ទំនងជាមួយនគរចេនឡា តែពេលមកដល់ខេត្តមួយក្នុងនគរចម្ប៉ា ត្រូវបានគេឃុំទុកមិនឱ្យត្រឡប់ទៅស្រុកវិញ។ រឿងនេះធ្វើឱ្យព្រះចៅក្រុងចិនយល់ច្រឡំថានគរចេនឡាមានចេតនាប្រឆាំងនឹងនគរចិន។ លើសពីនេះទៅទៀត ទ្រង់យល់ដោយច្រឡំ **នគរចម្ប៉ា** បានឆក់ប្លន់អំណោយរបស់នគរចេនឡាជូនទៅនគរចិនទៀតផង។

### ២.២.៤-ទំនាក់ទំនងវិស័យយោធា

ក្នុងអំឡុងចុងសតវត្សទី១២និងដើមសតវត្សទី១៣ តាមរយៈកំណែទម្រង់វិស័យយោធាឱ្យកាន់តែមានសក្តានុពល **ព្រះបាទជ័យវរ្ម័នទី៧** បានខិតខំប្រឹងប្រែងរំដោះប្រទេសជាតិពីនគរ

(២២) វ៉ូ គ័ងហ៊្វូ ៖ **ទំនាក់ទំនងរបស់រជ្ជកាលយាន និងប្រទេសចេនឡា នៅក្នុងសន្និសីទអន្តរជាតិលើកទី១ ស្តីពីទំនាក់ទំនងកម្ពុជា-ចិននាសម័យចេនឡានិងអង្គរ**, រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១ ទំព័រទី១០៧-១០៨។

ចម្ប៉ា។ ការកែទម្រង់វិស័យយោធានេះ បានបង្ហាញតាមរយៈចម្លាក់បុរាណដែលសិល្បករខ្មែរនាសម័យនោះបានឆ្លាក់ឡើងជាការចងចាំក្នុងប្រវត្តិសាស្ត្ររបស់ជាតិខ្លួន។ ចម្លាក់បុរាណលើជញ្ជាំងប្រាសាទ បានដើរតួជំនួសសៀវភៅប្រវត្តិសាស្ត្រ។



ចម្លាក់មេទ័ពចិននៅប្រាសាទបាយ័ន (ប្រភព ៖ www.cen.com.kh)

ក្នុងវិស័យយោធា វិធានការដែលធ្វើឱ្យកងទ័ពចាមរង្គោះរង្គើ ហើយនៅទីបំផុតក៏ច្បាំងចាញ់ខ្មែរ គឺការប្រើអាវុធថ្មីៗ ដូចជាស្នាយន្ត និងសំណាញ់(រូបចម្លាក់នៅលើប្រាសាទអង្គរវត្ត)។ ទន្ទឹមនឹងនោះ គេឃើញមាន **<u>វត្តមានរបស់មេទ័ពចិន</u>** ជាទីប្រឹក្សាយោធាដែលបានធ្វើឱ្យស្ថានភាពទ័ពខ្មែរកាន់តែរឹងប៉ឹង ឯទឹកចិត្តប្រយុទ្ធក៏ត្រូវបានលើកម្ពស់ឡើងមួយកម្រិតថែមទៀតផង។ លើសពីនេះទៅទៀត គេឃើញមានវត្តមានរបស់កងទ័ពចិនដើរក្បួន ក្នុងរជ្ជកាលរបស់ **ព្រះបាទសុរិយាវរ្ម័នទី២** នៅលើប្រាសាទអង្គរវត្តដែរ។ ចម្លាក់នៃកងទ័ពចិនទាំងនោះ គឺជាតឹកតាងមួយយ៉ាងសំខាន់ ដែលបង្ហាញជាប្រយោលនូវនយោបាយបែប **«ចងសម្ព័ន្ធភាព»** ជាមួយ

បរទេស ជាពិសេសជាមួយមហាមិត្តចិនដោយសាមគ្គីភាពនិងភាតរភាពយ៉ាងជ្រាលជ្រៅ។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ដែលបានឆ្លាក់នៅលើជញ្ជាំងនៃប្រាសាទបាយ័នបានបង្ហាញកិច្ចការសហការលើវិស័យយោធារវាងខ្មែរនិងទីប្រឹក្សាចិន។ នេះមិនមែនជាបញ្ហាគួរឱ្យភ្ញាក់ផ្អើលឡើយ ព្រោះវាជាប្រពៃណីអចិន្ត្រៃយ៍នៃទំនាក់ទំនងកម្ពុជា-ចិន។

## ២.៣-សេដ្ឋកិច្ច

### ២.៣.១-ពាណិជ្ជកម្ម

#### ក-កាក់ចិន

វត្ថុផ្សេងៗឬទំនិញខ្មែរទាំងអស់នៅសម័យកាលនោះប្រហែលជាត្រូវបានជួញដូរដោយប្រើ **កាក់** ធ្វើជារូបិយវត្ថុ។ ដោយតម្រូវឱ្យមានការទិញ ដូចជា វត្ថុធាតុដើមពីខ្មែរ ជនជាតិចិនត្រូវប្រើកាក់ ដូចជាកាក់បុរាណមួយចំនួនដែលគេរកឃើញក្នុងរាជធានីបុរាណខ្មែរមួយក្នុងរាជ-



កាក់ចិន (ប្រភព ៖ បណ្ឌិត មីសែល ត្រាណេ)

ធានីនាសម័យនោះ(បច្ចុប្បន្នស្ថិតនៅក្នុងទីក្រុង **អ៊ូថង** ខេត្តសុផាន់បុរី ប្រទេសថៃសព្វថ្ងៃនេះ)។

កាក់ចិនទាំងនោះ គឺជាកាក់ដែលត្រូវបានផលិតឡើងនៅប្រទេសចិន ហើយក្នុងរាជ្យរបស់ស្តេច **វូឌី** មានកាលបរិច្ឆេទរវាងឆ្នាំ១២០ មុនគ្រិស្តសករាជ។ ចម្លាក់កាក់ចិនត្រូវបានបន្តរហូតដល់សម័យក្រោយអង្គរ ព្រោះថាកាក់រាប់ពាន់នាសម័យ **មីញ** ត្រូវបានជួបប្រទះតាមទីប្រជុំជនខ្មែរនៅពេលបច្ចុប្បន្ន ក៏ដូចជាក្នុងអតីតដែនដីខ្មែរដែរ[២៣]។

## ខ-ប្រាក់ស្លឹង

ជាការជាក់ស្តែង **ប្រាក់ស្លឹងខ្មែរ** ត្រូវបានផលិតឡើងនៅក្នុងសម័យរបស់ **ស្តេចកន** ឬ **ព្រះបាទស្រីជេដ្ឋាធិរាជរាមាធិបតី** (១៥១២-១៥២៦) ដើម្បីអភិវឌ្ឍប្រទេសឱ្យស្របនឹងស្ថានភាពសេដ្ឋកិច្ច។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ពុំមែនមានន័យថានេះជាលើកទីមួយដែលប្រជាជនខ្មែរចេះប្រើប្រាស់ជារូបិយវត្ថុ។

ពាក្យ **ស្លឹង** និងតម្លឹងត្រូវបានគូសបញ្ជាក់ ដោយសិលាចារឹកមួយចំនួននាសម័យបុរេអង្គរ និងអង្គរ ទោះបីជាទូទៅការទិញដូរធ្វើដោយមាសឬវត្ថុមានតម្លៃ ដូចជា ចាន ឆ្នាំង សំពត់ និងសត្វពាហនៈក៏ដោយ ។



ប្រាក់ស្លឹង (ប្រភព ៖ បណ្ឌិត មីសែល ត្រាណេ)

(២៣) www.cen.com.kh/Culture

ជាការពិតណាស់ នៅប្រទេសខ្មែរនាសម័យហ្វូណនពីសតវត្សទី១ដល់សតវត្សទី៧ មានការប្រើប្រាស់កាក់ធ្វើអំពីមាស ប្រាក់ ស្ពាន់ និងសំណរួចស្រេចទៅហើយ។ ដូច្នេះ ការណ៍ដែលគេអះអាងថា **ស្តេចកន** បានបោះពុម្ពប្រាក់ស្លឹងជាលើកដំបូងបង្អស់ គឺមិនត្រឹមត្រូវនោះទេ។ **ប្រាក់ស្លឹង** ដែលត្រូវបានផលិតឡើងក្នុងរាជ្យរបស់ **ស្តេចកន** (២៤) មានរាងតូចមូល ហើយមាន រូបចម្លាក់ផ្សេងៗតែម្ខាង រីឯវិមាត្ររបស់វាគឺ១៥មីលីម៉ែត្រ ដោយមានទម្ងន់ប្រមាណជា ៣,៧៥ក្រាម ដោយមានរូបមាន់ ក្ដាម គ្រុឌ ហង្ស ទន្សាយ សេះ ប្រើស ពស់ ផ្កា និងបេះដូង។ល។

គប្បីត្រូវជ្រាបផងដែរថា រូបិយវត្ថុខ្មែរនាសម័យក្រោយអង្គរ ត្រូវបានចែកចេញជាបីសម័យកាលធំៗគឺដំណាក់កាលទីមួយគឺ ១៥០០ដល់១៦៥០ ដំណាក់កាលទីពី គឺ១៦០០ ដល់១៨៧០ និងដំណាក់កាលទីបីគឺ១៨៧០ ដល់១៩០៧ ដែលស្ថិតក្នុងសម័យកាល លោកម្ចាស់គ្រប់គ្រងខេត្តបាត់ដំបង។ អ្វីដែលគួរកត់ត្រាគឺក្នុងដំណាក់កាលទីបី ដែលបានបន្តវេនពីសម័យកាលមុនៗដែលបោះប្រាក់មួយប្រភេទឈ្មោះប្រាក់ពៃដែលភាគច្រើនដូចសម័យមុនៗ លម្អដោយសត្វហង្ស ឬមាន់តែមានចារអក្សរចិនមួយតួនៅពីលើគឺ (吉) ដែលមានន័យថាសុភមង្គល(២៥)។



រូបសំណាក
នៅក្នុងបរិវេណ
នៃព្រះរាជា

## ២.៣.២-ដៃគូអភិវឌ្ឍ

នៅក្នុងទំនាក់ទំនងអភិវឌ្ឍជាតិក្រៅពីរង្វង់នៃថ្នាក់ដឹកនាំ ប្រជាពលរដ្ឋនៃប្រទេសយើងទាំងពីរក៏មានទំនាក់ទំនងល្អនឹងគ្នាផងដែរ។ ដោយសារភូមិសាស្ត្រកម្ពុជាមានអំណោយផលរ៉ែមាស និងធនធានធម្មជាតិសំបូរបែបរួមផ្សំជាមួយប្រជាពលរដ្ឋនៅមានចំនួនតិច ជនជាតិចិនបានសម្រេចចិត្តមកកាន់ប្រទេសកម្ពុជា ដើម្បីចូលរួមជាមួយនឹងប្រជាពលរដ្ឋកម្ពុជាក្នុងកិច្ចអភិវឌ្ឍជាតិ។

ជនជាតិចិនដែលប្រកាន់ខ្ជាប់នូវទស្សនៈ ដែលថា «ស្លឹកជ្រុះរកគល់ អ្នកថ្លៃថ្នូរត្រូវត្រលប់មកស្រុកកំណើត» មិនត្រូវបានអនុវត្តនៅ

---

(២៤) សូមមើល រស់ ចន្ត្រាបុត្រ ៖ **ព្រះស្តេចកន**, ភ្នំពេញ ឆ្នាំ២០០៦

(២៥) www.cen.com.kh/Culture

ពេលដែលពួកគេបានធ្វើដំណើរមកដល់កម្ពុជា។ ជនជាតិចិនរស់នៅប្រទេសកម្ពុជា មានទឹកចិត្តស្រលាញ់ទឹកដីដ៏ស្រស់ស្អាតនេះ និងមានទំនាក់ទំនងសុខដុមរមនាជាមួយប្រជាពលរដ្ឋកម្ពុជា។ «ចូលស្ទឹងតាមបត់ ចូលស្រុកតាមទេស» បានក្លាយជាពាក្យស្លោកយ៉ាងពេញនិយម ដែលជនជាតិចិនបានអនុវត្តនៅកម្ពុជា។ ជនជាតិចិនបានចាត់ទុកកម្ពុជាគឺជាផ្ទះរបស់ពួកគេ ហើយពួកគេរស់នៅចាក់គ្រឹះនិងបន្តពូជពង្ស។ នេះមិនមែនមានន័យថាជនជាតិចិនដណ្តើមយកទឹកដីកម្ពុជានោះទេ ផ្ទុយទៅវិញ ពួកគេបានរួមចំណែកក្នុងកិច្ចអភិវឌ្ឍជាតិរបស់កម្ពុជា។ លើសពីនេះទៅទៀត ថ្នាក់ដឹកនាំរបស់ចិនតែងនឹករឭកដល់ជនជាតិចិនដែលនៅកម្ពុជា ហើយបានជួយការពារអធិបតេយ្យភាព និងភាពសុខសាន្តរបស់កម្ពុជាទៀតផង។ ទំនាក់ទំនងរវាងកម្ពុជានិងចិន គឺជាទំនាក់ទំនងមិត្តភាពលើវិស័យវប្បធម៌ និងសេដ្ឋកិច្ចជាងវិស័យនយោបាយ។ ដើម្បីឆ្លើយតបនឹងកិច្ចរួមចំណែករបស់ជនជាតិចិន ថ្នាក់ដឹកនាំកម្ពុជាតែងប្រកាន់ខ្ជាប់នូវកិច្ចការពារជនជាតិចិន (សូមអានចំណុច២.២.៣)។



ព្រះស្តេចគន
ក្រសួងពាណិជ្ជកម្ម
ណាចក្រកម្ពុជា

ដោយសារតែជនជាតិចិនមានអត្តចរិតស្លូតត្រង់ សុចរិត អត់ធន់ ឧស្សាហ៍ព្យាយាម ទើបពួកគេទទួលបានការគោរពនិងជឿជាក់ពីប្រជាពលរដ្ឋខ្មែរ។ ជាបណ្តើរៗ ចរិតដ៏ល្អរបស់ជនជាតិចិនបានជំរុញប្រជាពលរដ្ឋខ្មែរមួយចំនួនធំបានផ្សំផ្គុំកូនចៅរបស់គេជាមួយនឹងជនជាតិចិន។ តាមរយៈអាពាហ៍ពិពាហ៍ និងការរស់នៅក្នុងភូមិស្រុកជាមួយជនជាតិចិន ជនជាតិខ្មែរបានទទួលយកប្រពៃណីរបស់ជនជាតិចិន។ ប្រពៃណីជនជាតិចិននេះបានដក់ជាប់នៅក្នុងចិត្តរបស់ជនជាតិខ្មែរមួយចំនួនធំ (ជាពិសេសអ្នកនៅទីប្រជុំជន ព្រោះជនជាតិចិនជាអ្នកជំនួញដែលរស់នៅទីប្រជុំជន) តាំងពីបុរាណកាលរៀងមក។ ក្នុងន័យនេះប្រជាពលរដ្ឋខ្មែរបានកែសម្រួលការទទួលយកវប្បធម៌ឥណ្ឌាមកទទួលយកវប្បធម៌ចិន។ ចង់ឬមិនចង់កម្ពុជាមិនអាចមិនទទួលយកវប្បធម៌នៃប្រទេសទាំងពីរនេះបានឡើយក្នុងពេលដែលកម្ពុជាស្ថិតនៅក្នុងភូមិសាស្ត្រឥណ្ឌូ-ចិននេះ ៕

# សន្និដ្ឋាន

ផ្ដើមពីភូមិផងរបងជាប់គ្នា ទំនាក់ទំនងកម្ពុជា-ចិនបានរីកធំធាត់ជាលំដាប់។ តាមរយៈទំនាក់ទនងដ៏ស្មោះត្រង់ និងកិច្ចការពារផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ឥទ្ធិពលនៃវប្បធម៌នៃប្រទេសទាំងពីរ កម្ពុជា-ចិន បាននាំឱ្យគ្នាទៅវិញទៅមក ប៉ុន្តែ ដោយសារប្រទេសចិនមានភាពចំណាស់ជាងប្រទេសកម្ពុជា ជាហេតុនាំឱ្យវប្បធម៌ចិនជាច្រើនបានហូរចូលមកប្រទេសកម្ពុជា។

ពីទំនាក់ទំនងដ៏ជិតស្និទ្ធពីអតីតកាល បានក្លាយជាបច្ច័យដល់ទំនាក់ទំនងនាពេលបច្ចុប្បន្ននិងអនាគត។ ស្ពានទំនាក់ទំនងនាសម័យហ្វូណនបានតភ្ជាប់កម្ពុជាទៅនឹងប្រទេសចិន ដែលជាប្រទេសមហាអំណាចនៅអាស៊ីដ៏មានឥទ្ធិពលនាពេលបច្ចុប្បន្ន។

ទំនាក់ទំនងរវាងកម្ពុជា-ចិន ជាទំនាក់ទំនងមិត្តភាពនិងកិច្ចសហប្រតិបត្តិការលើវិស័យវប្បធម៌និងពាណិជ្ជកម្ម។ ប្រទេសទាំងពីរបានសាងស្ពានទំនាក់ទំនងនេះ មិនត្រឹមតែដើម្បីប្រយោជន៍របស់ប្រទេសរៀងៗខ្លួនប៉ុណ្ណោះទេ តែថែមទាំងបង្ហាញដល់មនុស្សជាតិពីអារ្យធម៌ដ៏រុងរឿងរបស់ជនជាតិអាស៊ីទៀតផង។

ឯកសារ **ពាន់ឆ្នាំនៃទំនាក់ទំនងកម្ពុជា-ចិន** គឺជាផ្លូងដាស់ស្មារតីមិត្តភាពរបស់ជនជាតិយើងទាំងពីរឱ្យបន្តមូលដ្ឋានទំនាក់ទំនងពីបុរាណ ដើម្បីភាពរុងរឿងនៃបច្ចុប្បន្នភាពនិងអនាគតភាពរបស់ទ្វីបអាស៊ី។ ទំនាក់ទំនងនេះក៏ជាសារនយោបាយមួយដល់ប្រទេសជិតខាងរបស់កម្ពុជា ឱ្យយកគំរូពីវីរភាពរបស់វា។ ឯកសារនេះនឹងក្លាយជាប្រទីបថ្មីមួយដល់អ្នកការទូតវ័យក្មេងនៃប្រទេសយើងទាំងពីរ។

ទស្សនៈ **ការពារតែមិនវាយប្រហារ** ជាទស្សនវិជ្ជានយោបាយដែលថ្នាក់ដឹកនាំរបស់ប្រទេសយើងទាំងពីរ កម្ពុជា-ចិន បានអនុវត្តរៀងរហូតមក។ ជាមួយគ្នានេះ ទស្សនៈ **មិត្តល្អជាមិត្តដែលជួយគ្នាក្នុងគ្រាក្រ** ជាទស្សនៈប្រកបដោយគុណធម៌និងសីលធម៌ដែលថ្នាក់ដឹកនាំនិងជនជាតិយើងទាំងពីរបាននិងកំពុងតែអនុវត្ត។



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ត្រូវបានទទួលបដិសណ្ឋារកិច្ចដោយ
ឯកឧត្តម ហ៊ូ ជីនតាវ ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន
នាទីក្រុងប៉េកាំង កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០

2010年12月15日，中国国家主席胡锦涛阁下
在中国北京接见在中国访问的柬埔寨王国政府首相洪森亲王



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
បានទទួលបដិសណ្ឋារកិច្ច
ឯកឧត្តម ហ្ស៊ី ជីនពីង អនុប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន
នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩

2009年12月21日，柬埔寨王国政府首相洪森亲王
迎接到柬埔寨金边访问的中国国家副主席习近平阁下

| | | |
|---|---|---|
| **ទីប្រឹក្សា** | | 顾问 |
| 1-លោកជំទាវបណ្ឌិតសភាចារ្យ | **ខ្លួត ធីតា** | 克罗提达院士 |
| 2-ឯកឧត្តមបណ្ឌិតសភាចារ្យ | **តិច សំណាង** | 德松南院士 |
| 3-ឯកឧត្តមបណ្ឌិត | **មាស សំអុល** | 密松沃博士 |
| 4-ឯកឧត្តមបណ្ឌិត | **ម៉ៅ សុផាន់** | 毛速潘博士 |
| **ក្រុមត្រួតពិនិត្យ** | | 编委会 |
| 1-ឯកឧត្តមបណ្ឌិត | **ស៊ុន ហួរ** | 谢顺华博士 |
| 2-ឯកឧត្តមបណ្ឌិត | **គឹម យឿន** | 金源博士 |
| 3-ឯកឧត្តម | **ណួត ខាន់** | 诺坎阁下 |
| 4-ឯកឧត្តម | **កែវ សេងឡាយ** | 高成来阁下 |
| 5-ឯកឧត្តម | **ម៉ម ឈាង** | 满强阁下 |
| 6-ឯកឧត្តម | **ឌួង លាង** | 杨世明阁下 |
| 7-ឯកឧត្តម | **ស៊ឹម ហ៊ាង** | 盛贤阁下 |
| 8-លោក | **អ៊ុន សុធន** | 温速通先生 |
| 9-លោក | **ជា ចេងឃុន** | 谢进群先生 |
| 10-លោក | **ទិត្យ រចនា** | 林德虎先生 |
| 11-លោក | **វង្ស មេង** | 王明先生 |
| 12-លោក | **ឈិន ទី** | 陈迪先生 |
| **ក្រុមស្រាវជ្រាវ** | | 研究工作组 |
| 1-លោកបណ្ឌិត | **ជា មុនីឫទ្ធិ** | 谢莫尼乐博士 |
| 2-លោក | **វ៉ង ស៊ានមាវ** | 王贤淼先生 |
| 3-លោកស្រី | **កែវ ខេមរា** | 高和平女士 |
| 4-លោក | **ជា មុនីរតនា** | 谢伟强先生 |
| **ក្រុមបកប្រែ** | | 翻译组 |
| 1-លោកស្រី | **ដោក ចន្ធី** | 杜珍蒂女士 |
| 2-លោក | **ឡុក សុចាន់ណា** | 骆兆明先生 |
| 3-កញ្ញា | **ចាង ឈុនជី** | 张春子小姐 |
| 4-លោក | **អ៊ី ឈីហ័រ** | 余启华先生 |
| 5-កញ្ញា | **ឈឹង ស៊ាវវៃ** | 成晓薇小姐 |
| **បច្ចេកទេសកុំព្យូទ័រ** | | 电脑排版 |
| 1-លោក | **ប្រា បញ្ញា** | 巴拉班亚先生 |
| 2-លោក | **ជា មុនីរ័ត្ន** | 谢莫尼洛先生 |



លោកបណ្ឌិត **ជា មុនីឫទ្ធិ** នាយកវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា
ទទួលពានរង្វាន់ស្លាកមាសរបស់វិទ្យាស្ថានខុងជឺទីស្នាក់ការកណ្ដាលពីលោកជំទាវ **លីវ យានតុង**
ទេសរដ្ឋមន្ត្រីទទួលបន្ទុកអប់រំនិងវប្បធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាល
នៃវិទ្យាស្ថានខុងជឺទីស្នាក់ការកណ្ដាល ក្នុងឱកាសមហាសន្និបាតលើកទី៦ របស់វិទ្យាស្ថានខុងជឺ
នៅទីក្រុងប៉េកាំង កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១

2011年12月12日，中国国务委员、孔子学院总部理事长刘延东女士
在孔子学院总部向柬埔寨王家研究院孔子学院柬方谢莫尼乐颁发全球优秀孔子学院奖牌